# ក

## មាតិកា

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 11 ខែ 06 ឆ្នាំ 2003

### I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

០២-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៤៦ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ជូនសមាជិក សមាជិកា ព្រឹទ្ធសភាចំនួន ៦០រូប ២៦២៤

០២-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៤៧ស្តីពីការតែងតាំងឯកឧត្តម **អៀត សុខ** ជាប្រធានក្រុមប្រឹក្សាអ្នកច្បាប់អមអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានឋានៈស្មើអនុរដ្ឋលេខាធិការ ជំនួសលោកជំទាវ **ជេត ចណ្ណាលី** ២៦២៩

០៤-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៤៩ ស្តីពីការបំពាក់មេដាយសេនាជ័យសិទ្ធ ជូនដល់នាយទាហានជាន់ខ្ពស់ ចំនួន ០២-រូប ២៦៣០

០៤-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៥០ ស្តីពីការលើកលែងទោសឱ្យទណ្ឌិតឈ្មោះ **នួន កែវចណ្ណា** ២៦៣១

០៤-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៥១ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ចាង ហ្វេងមីង** (CHANG FENG MING) ហៅ **ថូមី ចាង** (TOMMY CHANG) សញ្ជាតិដើមចិន ២៦៣២

០៥-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៥២ ស្តីពីការតែងតាំង ឯកឧត្តម **វស់ ឆេង** ជាទីប្រឹក្សាសម្តេចក្រុមព្រះប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ២៦៣៣

០៥-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៥៣ ស្តីពីការតែងតាំង ឯកឧត្តម **ថោង ឈិន** ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកការងារសង្គមកិច្ចនិងអភិវឌ្ឍន៍ជនបទ ២៦៣៤

០៥-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៥៤ ស្តីពីការតែងតាំង ឯកឧត្តម **សរ សម្បត្តិ** ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកកិច្ចការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ២៦៣៥

០៥-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៥៥ ស្តីពីការតែងតាំង ឯកឧត្តម **មៅ ញ៉** ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកការពារប្រទេស ២៦៣៦

០៥-១០-២០០១ - ព្រះរាជក្រឹត្យ នស/រក់ត/១០០១/៣៥៦ ស្តីពីការតែងតាំង ឯកឧត្តម **ឡាច លៀង** ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកធន ធានមនុស្សបន្ថែមលើមុខងារបច្ចុប្បន្ន ២៦៣៧

០៥-១០-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៥៤ ស្តីពីការតែងតាំង ឯកឧត្តម **ទីម ស៊ីផា**

| | | |
|---|---|---|
| | ជាទីប្រឹក្សាសម្ដេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកវិស័យរុក្ខា-ប្រមាញ់ និងបរិស្ថាន | ២៦៣៨ |
| ១២-១០-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៦០ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **ចាង គួសិន** (CHANG KUO SHENG) សញ្ជាតិដើមចិន | ២៦៣៩ |


## II- រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


| | | |
|---|---|---|
| ០១-១០-២០០១ | - អនុក្រឹត្យលេខ ១០១ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មការសហប្រតិបត្តិការសេដ្ឋកិច្ច កម្ពុជា-ថៃ | ២៦៤០ |
| ០៤-១០-២០០១ | - អនុក្រឹត្យលេខ ១០២ អនក្រ.បក ស្ដីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | ២៦៤៤ |
| ០២-១០-២០០១ | - អនុក្រឹត្យលេខ ៤២៣ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី | ២៦៤៨ |
| ០៥-១០-២០០១ | - អនុក្រឹត្យលេខ ៤២៤ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី | ២៦៤៩ |
| ០៥-១០-២០០១ | - អនុក្រឹត្យលេខ ៤២៥ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី | ២៦៥០ |


### ២.សេចក្ដីសំរេច


| | | |
|---|---|---|
| ០៣-១០-២០០១ | -សេចក្ដីសំរេចលេខ ៥៨ សសរ ស្ដីពីការផ្ទេរសិទ្ធិរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ២៦៥១ |
| ០៤-១០-២០០១ | -សេចក្ដីសំរេចលេខ ៥៩ សសរ ស្ដីពីការបង្កើតគណៈកម្មការដើម្បីត្រៀមរៀបចំកិច្ចប្រជុំកំពូលអនុតំបន់វិសាលភាពទន្លេមេគង្គ | ២៦៥២ |
| ០៥-១០-២០០១ | -សេចក្ដីសំរេចលេខ ៦០ សសរ ស្ដីពីការលុបចោលសារាចរណែនាំរបស់ក្រសួងធម្មការ និងសាសនាលេខ ០៥ ក.ធ.ស.ស.ច .ចុះថ្ងៃទី ០២ ខែតុលាឆ្នាំ ២០០១ ស្ដីពីការរក្សាសណ្ដាប់ធ្នាប់របៀបរៀបរយនៃសាសនាឥស្លាមនៃព្រះរាជាណាចក្រកម្ពុជា | ២៦៥៤ |


## III- ការងារបណ្ដាក្រសួង

### ១.ធនាគារជាតិនៃកម្ពុជា


| | | |
|---|---|---|
| ០៤-១០-២០០១ | - ប្រកាសលេខ ធ.៨.០១-១៣៣.ប្រក ស្ដីពីរចនាសម្ព័ន្ធរបស់នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡានិងមុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ | ២៦៥៦ |
| ០៤-១០-២០០១ | - ប្រកាសលេខ ធ.៨.០១-១៣៣៤ប្រក ស្ដីពីរចនាសម្ព័ន្ធរបស់នាយកដ្ឋាន រោងពុម្ពនិងមុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ | ២៦៦៦ |
| ០៨-១០-២០០១ | - ប្រកាសលេខ ធ.៨.០១-១៣៥.ប្រក ស្ដីពី គោលការណ៍សមាហរណកម្មមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជានៅក្នុងក្របខ័ណ្ឌថ្មី | ២៦៧៤ |

## ២~ ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០៧-១០-២០០១ - ប្រកាសលេខ ២៦៧ MoC/M2001 ស្តីពីការដាក់ឱ្យដេញថ្លៃលើកូតាសំលៀកបំពាក់ដែល ត្រូវបាននាំចេញទៅកាន់សហរដ្ឋអាមេរិក សំរាប់ឆ្នាំ ២០០១ ២៦៩២

07-10-2001 - PRAKAS No 267 MoC/ M 2001 On The Tender for Quota on Garments to be Exported to the United States in FY 2001 ២៦៩៧


## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល


០៤-១០-២០០១ - ប្រកាសលេខ ៦៥៣ ឧរថ.កឧ.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន ឌីអេ ខបភើរេសិន អិលធីឌី (D.A CORPORATION , LTD.) តំណាងដោយលោក CHUNG BYUNG MIN សញ្ជាតិកូរ៉េ បង្កើតរោងចក្រ " ចាក់សំលៀកបំពាក់ " ដែលមានឈ្មោះថា " ឌីអេ ខបភើរេសិន " មានទីតាំងស្ថិតនៅដីឡូតិ៍ លេខ ៣១១ ផ្លូវលេខ ២៧១ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ២៧០១

០៤-១០-២០០១ - ប្រកាសលេខ ៦៥៤ ឧរថ.កឧ.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន យេន យូអ៊ិនហ្គាមេន (ខេមបូឌា) ខូអិលធីឌី ( GENUINE GAEMENT (CAMBODIA) Co;LTD.) តំណាងដោយលោក YEH SHENG MAO សញ្ជាតិចិន (តៃវ៉ាន់) បង្កើត រោងចក្រ " កាត់ដេរសំលៀកបំពាក់ " ដែលមានឈ្មោះថា " យេនយូអ៊ិន ហ្គាមេន (ខេមបូឌា ) " មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ ភូមិគល់ ឃុំកន្ទោល ស្រុកអង្គស្នួល ខេត្តកណ្តាល ២៧០៣


## ៣~ ទីស្តីការរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា~ ព្រឹទ្ធសភា និង អធិការកិច្ច


០២-១០-២០០១ - សេចក្តីសំរេចលេខ ០០៦ /០១ ទ.រ.ព.អ . សសរ ស្តីពីការបង្កើតគណៈកម្មការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលនៅក្នុងក្របខ័ណ្ឌថ្មី ២៧០៥

# ព្រះរាជក្រឹត្យ

នស / រកត / ១០០១ / ៣៤៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រឹទ្ធសភា នីតិកាលទី ១
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៤ ចុះថ្ងៃ ទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៦៨ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៩ និង ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៦៩ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងសមាជិកព្រឹទ្ធសភា សំរាប់នីតិកាលទី ១
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំរបស់ប្រធានព្រឹទ្ធសភា ។ល។

# ត្រាស់បង្គាប់

មាត្រា១ : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ជូនសមាជិក សមាជិកា ព្រឹទ្ធសភាចំនួន ៦០ រូប ដូចមានរាយនាមខាងក្រោម :

ក/. **ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ " មហាសេនា "**

| | | |
|---|---|---|
| ១- ស្តេចក្រុមឃុន | **ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស** | អនុប្រធានទី១ព្រឹទ្ធសភា |
| ២- ឯកឧត្តម | **ញឹក ប៊ុនឆៃ** | អនុប្រធានទី២ព្រឹទ្ធសភា |
| ៣- ឯកឧត្តម | **គឹម សុខា** | ប្រធានគណៈកម្មការ ការពារសិទ្ធិមនុស្ស និង ទទួលពាក្យបណ្តឹង |
| ៤- ឯកឧត្តម | **ជា ម៉េងឈាង** | ប្រធានគណៈកម្មការ ហិរញ្ញវត្ថុ និងធនាគារ |
| ៥- ឯកឧត្តម | **ចាន់ គិន** | ប្រធានគណៈកម្មការ សេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្មអភិវឌ្ឍន៍ជនបទ និង បរិស្ថាន |
| ៦- ឯកឧត្តម | **ជា ដេត** | ប្រធានគណៈកម្មការ មហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត |
| ៧- លោកជំទាវ | **ទី បូរ៉ាស៊ី** | ប្រធានគណៈកម្មការ កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពត៌មាន |
| ៨- ឯកឧត្តម | **អ៊ុក ប៊ុនឈឿន** | ប្រធានគណៈកម្មការ នីតិកម្ម |
| ៩- ឯកឧត្តម | **គង់ គាំ** | ប្រធានគណៈកម្មការ អប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍ |
| ១០- ឯកឧត្តម | **ស៊ឹង អៀម** | ប្រធានគណៈកម្មការ សុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី |
| ១១- ឯកឧត្តម | **សាប៊ូ ឆាចា** | ប្រធានគណៈកម្មការ សាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម ។ល។ |

ខ/~ ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ " ធិបឌិន្ទ "

| | | |
|---|---|---|
| ១- ឯកឧត្តម | អ៊ុំ ធី | អនុប្រធានគណៈកម្មការ ការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្ដឹង |
| ២- លោកជំទាវ | ពុំ ស៊ីចាន់ | អនុប្រធានគណៈកម្មការ ហិរញ្ញវត្ថុ និង ធនាគារ |
| ៣- ឯកឧត្តម | ឃួន ហ្វ្រង់ | អនុប្រធានគណៈកម្មការ មហាផ្ទៃ ការពារ ជាតិ អង្កេត និងបោសសំអាត |
| ៤- ឯកឧត្តម | ស៊ើរ កុសល | អនុប្រធានគណៈកម្មការ កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពត៌មាន |
| ៥- ឯកឧត្តម | ខៀវ សន | អនុប្រធានគណៈកម្មការនីតិកម្ម |
| ៦- ឯកឧត្តម | ពៅ សាម៉ាត | អនុប្រធានគណៈកម្មការ អប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍ |
| ៧- ឯកឧត្តម | ឈា ថាំង | អនុប្រធានគណៈកម្មការ សុខាភិបាល សង្គមកិច្ចការងារ និងកិច្ចការនារី |
| ៨- ឯកឧត្តម | ឈិត គីមយាត | អនុប្រធានគណៈកម្មការ សាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម |
| ៩- លោកជំទាវ | ម៉ែន ម៉ាលី | លេខាធិការគណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្ដឹង |
| ១០- ឯកឧត្តម | ឆាយ ប៊ុនឡាយ | លេខាធិការគណៈកម្មការ ហិរញ្ញវត្ថុ និង ធនាគារ |
| ១១- ឯកឧត្តម | អ៊ុក ប្រាថ្នា | លេខាធិការគណៈកម្មការ សេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និង បរិស្ថាន |
| ១២- ឯកឧត្តម | សេក សំអៀត | លេខាធិការគណៈកម្មការ មហាផ្ទៃ ការពារ ជាតិ អង្កេត និងបោសសំអាត |

| | | |
|---|---|---|
| ១៣- ឯកឧត្តម | **ផៃ ស៊ីផាន** | លេខាធិការគណៈកម្មការ កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពតិមាន |
| ១៤- ឯកឧត្តម | **កែវ សាន** | លេខាធិការគណៈកម្មការនីតិកម្ម |
| ១៥- ឯកឧត្តម | **ស៊ឹម សូលី** | លេខាធិការគណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍ |
| ១៦- លោកជំទាវ | **សម កន្និដ្ឋា** | លេខាធិការគណៈកម្មការ សុខាភិបាល សង្គមកិច្ចការងារ និងកិច្ចការនារី |
| ១៧- ឯកឧត្តម | **ហាស សារ៉េន** | លេខាធិការគណៈកម្មការ សាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្មថាមពល និងពាណិជ្ជកម្ម |

គ/_ **ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ " សេនា "**

| | | |
|---|---|---|
| ១- ឯកឧត្តម | **កង ចន្ទ** | សមាជិក |
| ២- ឯកឧត្តម | **អ៊ឹក ម៉ឿន** | សមាជិក |
| ៣- ឯកឧត្តម | **ខ៉ាន់ ម៉ាត់** | សមាជិក |
| ៤- ឯកឧត្តម | **អ៊ូ ប៊ុនឡុង** | សមាជិក |
| ៥- ឯកឧត្តម | **ប្រាក់ ខ៉ាននី** | សមាជិក |
| ៦- ឯកឧត្តម | **ហ៊ុត ទ្រី** | សមាជិក |
| ៧- ឯកឧត្តម | **អ៊ឹង ស៊ឹម** | សមាជិក |
| ៨- ឯកឧត្តម | **ចៅ ផល្លី** | សមាជិក |
| ៩- ឯកឧត្តម | **ឆាំង សុង** | សមាជិក |
| ១០- ឯកឧត្តម | **ជា គីម** | សមាជិក |
| ១១- លោកជំទាវ | **ម៉ិច សុម៉ាលី** | សមាជិកា |
| ១២- ឯកឧត្តម | **ថាច់ សេដ្ឋា** | សមាជិក |
| ១៣- ឯកឧត្តម | **ហង់ ជួន** | សមាជិក |
| ១៤- ស្តេចក្រុមឃុន | **នរោត្តម សិរីវុឌ្ឍ** | សមាជិក ៧.ក. |

១៥- ឯកឧត្តម ស៊ិន ពិនសេន សមាជិក
១៦- លោកជំទាវ ម៉ាន សំអាន សមាជិក
១៧- ឯកឧត្តម ម៉េង រីតា សមាជិក
១៨- ឯកឧត្តម ប៉ើយ កើត សមាជិក
១៩- ឯកឧត្តម ខៀវ សួន សមាជិក
២០- ឯកឧត្តម រុង ផ្លាមកេសន សមាជិក
២១- ឯកឧត្តម គួច សារ៉ន់ សមាជិក
២២- ឯកឧត្តម អៀវ បណ្ណាការ សមាជិក
២៣- ឯកឧត្តម ស៊ើយ កែវ សមាជិក
២៤- លោកជំទាវ កែវ ប៊ុនធូក សមាជិកា
២៥- លោកជំទាវ ឈុក ឈឹម សមាជិកា
២៦- ឯកឧត្តម ឆេព ចន សមាជិក
២៧- ឯកឧត្តម ម៉ែន សារុន សមាជិក
២៨- ឯកឧត្តម ស៊ឹម កា សមាជិក
២៩- ឯកឧត្តម ប៉ែន ផាត់ សមាជិក
៣០- ឯកឧត្តម លី គឹមហាន សមាជិក
៣១- ឯកឧត្តម រស់ ស្រេង សមាជិក
៣២- ឯកឧត្តម ថុង ចន់ សមាជិក

មាត្រា២ : ប្រធានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ២៤១ ន.ស

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០១

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ១០ ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

# ព្រះរាជក្រឹត្យ

យើង

នស/រកត/១០០១/៣៤៧

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការនូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១-១២-១៣-១៨-២២-២៤-២៦ ២៨-៣០-៣៤-៥១-៩០-៩១-៩៣ និង មាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម អៀង សុខ ជាប្រធានក្រុមប្រឹក្សាច្បាប់អមអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានឋានៈស្មើ អនុរដ្ឋលេខាធិការ ជំនួសលោកជំទាវ ថេត ចន្ទ្រាលី ដែលត្រូវផ្លាស់ទៅបំពេញភារកិច្ចថ្មី ។

**មាត្រា ២ :** ចំណុចទី ២ ក្នុងមាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៥ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ៣៤៧ ន.ស

ដើម្បីថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៤៩

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : បំពាក់មេដាយ សេនាជ័យសិទ្ធ ជូនដល់នាយទាហានជាន់ខ្ពស់ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១- ឧត្តមសេនីយ៍ឯក ឡាយ អ៊ីភិសិដ្ឋ អត្តលេខ ០០០២៣៥ អនុរដ្ឋលេខាធិការក្រសួងការពារជាតិ

២- ឧត្តមសេនីយ៍ឯក ជុំ សម្ប៊ុន អត្តលេខ ០០០២៤១ អនុរដ្ឋលេខាធិការក្រសួងការពារជាតិ

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១

លេខ: ៧៥០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១

ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៥០

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស

បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : លើកលែងទោសឱ្យទណ្ឌិតឈ្មោះ **នួន កែវវណ្ណា** ដែលបានកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស ។

ទណ្ឌិតឈ្មោះ **នួន កែវវណ្ណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១៨ ខែ តាមអំណាចសាលក្រមលេខ ០៥ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០០០ របស់តុលាការយោធា ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ៧៥១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/១៩៦

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចាង ហ្វេងមីង** ( CHANG FENG MING ) ហៅ ថូមី ចាង ( TOMMY CHANG ) សញ្ជាតិដើមចិន កើតថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៥៦ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ៩៤៣ ន.ស

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០១

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៥២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៦៤៥ រស ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំងឯកឧត្តម **ឌស់ ឆេង** ជាទីប្រឹក្សាសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាម ព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ៣៥២ ច.ល

ភ្នំពេញ ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០១

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ [illegible] ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៥៣

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ

និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្ដីក្រាបបង្គំទូលស្នើសុំរបស់សម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៦៨៣ រស ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំងឯកឧត្ដម ង៉ោន ឈិន ជាទីប្រឹក្សាសម្ដេច ហេង សំរិន អនុប្រធានទី១រដ្ឋសភា ទទួលបន្ទុកការងារសង្គមកិច្ច និងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាម ព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

ព្រះហស្ដលេខា

នរោត្ដម សីហនុ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០១

លេខ: ២៤៥ ត.រស

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ១៧ ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស.រកត/១០០១/៣៥៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៦៨៣ រស ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០១

**ត្រាស់បង្គាប់**

**មាត្រា១.-** តែងតាំងឯកឧត្តម **សរ សម្បត្តិ** ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១រដ្ឋសភា ទទួលបន្ទុកកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២.-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ២៤៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៥៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៦៨៣ រស ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំងឯកឧត្តម ម៉ៅ ញាំ ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកការពារប្រទេស មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០១

លេខ: ២៤៧៦ .៣

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ១០ ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៥៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៦៨៣ រស ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០១

ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំងឯកឧត្តម ឡាច សៀង ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកធនធានមនុស្ស បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា

**នរោត្តម សីហនុ**

លេខ: ២៤៩ ...

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៥៧

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្ដីក្រាបបង្គំទូលស្នើសុំរបស់សម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៦៨៣ រស ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា១.-** តែងតាំងឯកឧត្តម ឆឹម ស៊ីដា ជាទីប្រឹក្សាសម្ដេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកវិស័យរុក្ខា-ប្រមាញ់ និងបរិស្ថាន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២.-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា

នរោត្តម សីហនុ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០១

លេខ: ២៤៨

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែ ១០ ឆ្នាំ ២០០១

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៦០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ចាង គួសឹង (CHANG KUO SHENG) សញ្ជាតិដើមចិន កើតថ្ងៃទី ១៣ ធ្នូ ឆ្នាំ ១៩៤៩ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ២៥៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០១

សុខ អាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** : ១០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការសហប្រតិបត្តិការសេដ្ឋកិច្ច កម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- តាមការចាំបាច់

## សំរេច

**មាត្រា ១ .-**

អនុក្រឹត្យនេះកំណត់ការបង្កើតគណៈកម្មការសហប្រតិបត្តិការសេដ្ឋកិច្ច កម្ពុជា-ថៃដើម្បីរៀបចំកិច្ចព្រមព្រៀងក្របខ័ណ្ឌមួយ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ។

**មាត្រា ២ .-**

សមាសភាពគណៈកម្មការសហប្រតិបត្តិការសេដ្ឋកិច្ចនេះ មានដូចខាងក្រោម :

១- ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាប្រធាន

២- ឯកឧត្តម **ឈៀង យ៉ារណារ៉ា** អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធានទី១

៣- ឯកឧត្តម **សុក ស៊ីផាណា** រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម អនុប្រធាន

៤- ឯកឧត្តម **អ៊ុង គីមអន** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៥- ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

៦- ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

៧- ឯកឧត្តម **ស៊ូ សុវ៉ាត់** អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និង នេសាទ សមាជិក

៨- ឯកឧត្តម **តែ ដួងដារ៉ា** អគ្គលេខាធិការអាជ្ញាធរជាតិប្រេងកាត សមាជិក

៩- ឯកឧត្តម **ខ្លូត ទ័រន់ឌី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សមាជិក

១០- ឯកឧត្តម **សូ វិចធ័រ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១១- លោក **លឹម ច័ន** អគ្គនាយករងនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិក

១២- លោក **ខា ចណ្ណាដេត** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ សមាជិក

១៣- ឯកឧត្តម **ទៀវ ឆូរ៉ា** អគ្គនាយកបច្ចេកទេសក្រសួងពាណិជ្ជកម្ម លេខាធិការ

ប្រធានគណៈកម្មការអាចអញ្ជើញប្រធាន ឬ តំណាងស្ថាប័ន អាជ្ញាធរដែនដី ឱ្យចូលរួមប្រជុំការងារតាមការចាំបាច់ ។

**មាត្រា ៣ .-**

គណៈកម្មការនេះមានភារកិច្ចៈ

១- សិក្សាឯកសារ និង រៀបចំអនុសាសន៍ស្តីពីលទ្ធភាព និង គំរូផែនការអភិវឌ្ឍន៍រួមគ្នាកម្ពុជា- ថៃ ។

២- ធ្វើជាដៃគូចរចាជាមួយភាគី ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា- ថៃ ។

៣- រៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា- ថៃ ។

៤- រៀបចំផែនការសកម្មភាពសំរាប់អនុវត្តន៍កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ។

៥- រៀបចំកម្មវិធីនិង គំរោងវិនិយោគអាទិភាព ដើម្បីជំរុញការអនុវត្តន៍កិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

៦- សំរបសំរួលការងារជាមួយបណ្តាក្រសួង-ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ។

៧- ទំនាក់ទំនង និង ស្វែងរកធនធានហិរញ្ញវត្ថុ ពីអ្នកផ្តល់ជំនួយ និងផ្នែកឯកជនទាំងក្នុងប្រទេស និងទាំងក្រៅប្រទេស សំរាប់ធ្វើការសិក្សាស្រាវជ្រាវ និង អនុវត្តកម្មវិធី និងគំរោងអាទិភាព ។

៨- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល ។

គណៈកម្មការត្រូវរាយការណ៍អំពីលទ្ធផលការងារ ដូចមានចែងក្នុងចំណុចទី១ ដល់ចំណុចទី៧ខាងលើ ជូនរាជរដ្ឋាភិបាល ពិនិត្យ និង សំរេច ។

មាត្រា ៤ .-

គណៈកម្មាការនេះមានលេខាធិការដ្ឋាន ដែលមានទីស្នាក់ការនៅទីស្តីការក្រសួងពាណិជ្ជកម្ម ។ លេខាធិការដ្ឋាននេះមានភារកិច្ចដូចខាងក្រោម :

១- សំរបសំរួលដំណើរប្រព្រឹត្តទៅរបស់គណៈកម្មការ មានជាអាទិ ការរៀបចំផែនការការងារ ការរៀបចំកិច្ចប្រជុំ និង របៀបវារៈ នៃអង្គប្រជុំគណៈកម្មការ ។

២- សំរបសំរួល និង ទំនាក់ទំនងការងារជាមួយបណ្តាក្រសួង ដែលជាសមាជិកគណៈកម្មការ និង ជាមួយស្ថាប័នជាតិពាក់ព័ន្ធ ដទៃទៀត ។

៣- ជាដៃគូចរចា កិរិតបច្ចេកទេស ជាមួយភាគីថៃ ។

៤- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រធានគណៈកម្មការ ។

លេខាធិការដ្ឋាននេះត្រូវដឹកនាំដោយលេខាធិការមួយរូប និងជំនួយការមួយចំនួន តាមការចាំបាច់ ។ មន្ត្រីជំនួយការ ក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម ឬ ជាមន្ត្រីក្របខ័ណ្ឌ ដែលអាចស្នើសុំពីក្រសួងស្ថាប័ននានា របស់ រាជរដ្ឋាភិបាល ។

មាត្រា ៥ .-

បង្កើតក្រុមការងារនៅតាមក្រសួង ដែលជាសមាជិកនៃគណៈកម្មការ ដើម្បីសំរបសំរួល និងជួយការងារទាំងឡាយ របស់សមាជិកគណៈកម្មការ ។

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម :

១- ជាសមភាគីការងាររបស់លេខាធិការដ្ឋាន នៃគណៈកម្មការ ។

២- រៀបចំផែនការការងាររបស់ក្រសួងដែលទាក់ទងទៅនឹងកិច្ចសហប្រតិបត្តិការកម្ពុជា- ថៃ ។

៣- ពិនិត្យឯកសារដែលស្នើដោយភាគីថៃ ហើយដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នខ្លួន និងស្នើអនុសាសន៍ ។

៤- រៀបចំផែនការសកម្មភាពតាមវិស័យ សំរាប់អនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

៥- រៀបចំកម្មវិធី និងគំរោងវិនិយោគអាទិភាព តាមវិស័យដើម្បីជំរុញការអនុវត្តន៍កិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

មាត្រា ៦ .-

គណៈកម្មការសហប្រតិបត្តិការសេដ្ឋកិច្ចនេះ អាចប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម សំរាប់រាល់លិខិតផ្លូវការរបស់ខ្លួន និងមានថវិកាសំរាប់ការងាររបស់ខ្លួន ដែលផ្ញើជាមួយនឹងគណនីរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា២ និង អភិបាលខេត្ត-ក្រុង ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០១

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ចម ប្រសិទ្ធ**

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**កន្លែងទទួល**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងបរិស្ថាន ទៅជា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ/បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងបរិស្ថាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សំ រេ ច

មាត្រា ១ .-

ត្រូវបានតម្លើងនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុរបស់ក្រសួងបរិស្ថានទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ។

មាត្រា ២ .-

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទទួលបន្ទុក : គ្រប់គ្រងការងារ រដ្ឋបាល បូកសរុប របាយការណ៍ ឯកសារ បុគ្គលិក ផែនការ ហិរញ្ញវត្ថុ សម្ភារៈបរិក្ខារ សារពើភ័ណ្ឌ ការងារបណ្តុះបណ្តាល ក្របខ័ណ្ឌក្រសួង ការងារសិក្សាស្រាវជ្រាវ និងសុពលភាពការងារ សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលនៅក្នុងក្រសួង ជាមួយបណ្តាអង្គភាពមូលដ្ឋានខេត្ត-ក្រុង និងជាមួយបណ្តា ក្រសួងនានា ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយ អគ្គនាយករង ជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រសួងបរិស្ថានមាននាយកដ្ឋានចំណុះចំនួន ០៣ :-

១- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

២- នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

៣- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ។

មាត្រា ៣ .-

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ មានភារៈកិច្ច :

- សម្របសម្រួលកិច្ចការរបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយនឹងអង្គភាពមូលដ្ឋានក្រោមចំណុះ
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួងបរិស្ថាន
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង
- គ្រប់គ្រងការងារទំនាក់ទំនងអន្តរជាតិ ទំនាក់ទំនងសាធារណៈ និងកិច្ចការអាស៊ាន ។

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងអមដោយ អនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ ។

មាត្រា ៤ .-

នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស មានភារៈកិច្ច :

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព
- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង

- វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូងនិងបន្ត ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពត៌មានប្រតិបត្តិ
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង
- ទទួលកិច្ចការលើកសរសើរ និងជូនរង្វាន់ ។

នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងអមដោយអនុប្រធាននាយកដ្ឋាន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ៥ .-

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ មានភារៈកិច្ច :

- លើកគំរោងថវិកាក្រសួង និងតាមដានវិលើកពីការប្រតិបត្តិ
- ប្រមូលគំណូលអោយបានតាមស្របតាមច្បាប់ហិរញ្ញវត្ថុ
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា
- តាមដានវិលើកការគ្រប់គ្រងគណនីពិសេស
- ប្រមូលផ្តុំ និងសម្របសម្រួលរាល់ចំណាយរបស់ក្រសួង
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តន៍លទ្ធកម្មសាធារណៈ
- ប្រមូលផ្តុំតំរូវការធ្វើកម្មវិធី ចំណាយ គ្រប់គ្រងការរៀបចំជូសជុលសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ធ្វើកម្មវិធីចំណាយ បែងចែកប្រេងឥន្ទនៈ និងគ្រឿងបន្លាស់
- កាន់បញ្ជីជាប្រចាំនូវសាលាកប័ត្រ និងគណនេយ្យរូបធាតុ
- ពត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងអមដោយអនុប្រធាននាយកដ្ឋាន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ៦ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៧ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៨ .-

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី០៨ ខែ តុលា ឆ្នាំ ២០០១

រដ្ឋមន្ត្រី

សែន

បានយកសេចក្តីជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

បណ្ឌិត ម៉ុក ម៉ារ៉េត

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
  អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- ឯកសារ · កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤២.៣. អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក KIYOSHI AKIYAMA ( JICA EXPERT ) ជំនាញការជប៉ុន ដែលបានយកអស់កម្លាំងកាយចិត្ត និងចំណេះដឹងមកជួយការងាររួមរបស់មជ្ឈមណ្ឌលគ្រឿងចក្រធំៗ ជួយសាងសង់ផ្លូវថ្នល់ បណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេស បញ្ជូនមន្ត្រីរាជការអោយទៅរៀននៅប្រទេសជប៉ុន និង មានទំនាក់ទំនងជិតស្និទ្ធជាមួយមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ ក្នុងក្រសួងសាធារណការទាំងមូល អស់រយៈពេលបីឆ្នាំ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ [illegible] . ឆ្នាំ ២០០១

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤៧៤...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនអ្នកស្រី Misako Iwasaki ប្រធានអង្គការ J.V.C ដែលបានយកអស់កម្លាំងកាយចិត្ត ខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការងារគ្រប់គ្រង និងបណ្តុះបណ្តាលនិស្សិតខ្មែរ លើមុខវិជ្ជាជួសជុលរថយន្តគ្រប់ប្រភេទ ក្នុងរយៈពេលបីឆ្នាំ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ ១០ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤២៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក ALEXANDER BELOZYOROY តំណាងរបស់ស្ថាប័នចារកម្មក្រៅប្រទេស និង ជាលេខាទី ១ នៃស្ថានទូតសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មរយៈពេលជាង ៤ ឆ្នាំ ហើយសំរេចបានលទ្ធផលល្អប្រសើរ ក្នុងកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃ និង ស្ថាប័នចារកម្មក្រៅប្រទេសសហព័ន្ធរុស្ស៊ី ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៥៤...សសរ

# សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជារដ្ឋមន្ត្រីស្តីទីក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម ចម ប្រសិទ្ធ ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០១ រហូតដល់ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០១ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត-ក្រុង និងឯកឧត្តម ស៊ុយ សែម ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៩៦...អនក្រ

## សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការ

ដើម្បីត្រៀមរៀបចំកិច្ចប្រជុំកំពូល អនុតំបន់វិសាលភាពទន្លេមេគង្គ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ប្រការ១: បង្កើតគណៈកម្មការដើម្បីត្រៀមរៀបចំកិច្ចប្រជុំកំពូល នៃអនុតំបន់វិសាលភាពទន្លេមេគង្គ (Greater Mekong Sub-region - GMS) ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម **ហោ ណាំហុង** | ទេសរដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២-ឯកឧត្តម **ចម ប្រសិទ្ធ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣-ឯកឧត្តម **ឆាយ ថន** | រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ៤-ឯកឧត្តម **ឃឹម តាំងលីម** | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៥-ឯកឧត្តម **នួន ព័ន្ធមុនីរ័ត្ន** | ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ២:** គណៈកម្មការនេះមានភារកិច្ចរៀបចំ កិច្ចប្រជុំកំពូលអនុតំបន់វិសាលភាពទន្លេមេគង្គ (GMS) នៅភ្នំពេញ ដោយសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ កិច្ចប្រជុំនេះ នឹងត្រូវធ្វើមួយថ្ងៃមុន កិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ ២០០២ នៅភ្នំពេញ ។

**ប្រការ៣:** គណៈកម្មការនេះ នឹងសហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅភ្នំពេញ ដើម្បីរៀបចំកិច្ចប្រជុំកំពូលនេះ អោយបានជោគជ័យ ។

**ប្រការ៤:** ដើម្បីរៀបចំការងារអោយមានភាពប្រមូលផ្តុំចាប់ពីពេលនេះទៅ ឯកឧត្តម *ចម ប្រសិទ្ធ* អនុប្រធាន និង ឯកឧត្តម *អ៊ូន ព័ន្ធមុនីរ័ត្ន* សមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមរាល់កិច្ចប្រជុំដែលពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍អាងទន្លេមេគង្គ គឺអនុតំបន់វិសាលភាពទន្លេមេគង្គ (GMS) និង កិច្ចសហប្រតិបត្តិការអាស៊ាន ដើម្បីអភិវឌ្ឍន៍អាងទន្លេមេគង្គ (AMBDC) ។

**ប្រការ៥:** គណៈកម្មការនេះ នឹងបង្កើតលេខាធិការដ្ឋានមួយ ដែលមានទីតាំងនៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ក្នុងករណីចាំបាច់ ហើយមានសិទ្ធិអញ្ជើញអ្នកជំនាញឯកទេស មកពីបណ្តាក្រសួងស្ថាប័នដែលពាក់ព័ន្ធ អោយចូលរួមប្រជុំ ឬ ជួយបំពេញការងារ ក្នុងឋានៈជាជំនួយការខាងផ្នែកបច្ចេកទេស ។

**ប្រការ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង សាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៦០...ស.ស.រ

# សេចក្តីសំរេច

## ស្តីពី

## ការលុបចោលសារាចរណែនាំរបស់ក្រសួងធម្មការ និង សាសនា លេខ ០៥ ក.ធ.ស.ស.ច ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការរក្សាសណ្តាប់ធ្នាប់របៀបរៀបរយនៃសាសនាឥស្លាម នៃព្រះរាជាណាចក្រកម្ពុជា

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- យោងតាមការចាំបាច់

## សំរេច

**ប្រការ ១** : ត្រូវបានចាត់ទុកជាមោឃៈនូវសារាចរណែនាំរបស់ក្រសួងធម្មការ និង សាសនា លេខ ០៥ ក.ធ.ស.ស.ច ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការរក្សាសណ្តាប់ធ្នាប់របៀបរៀបរយនៃសាសនាឥស្លាម នៃព្រះរាជាណាចក្រកម្ពុជា ដោយមូលហេតុខ្លឹមសារនៃសារាចរនេះមិនស្របនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

**ប្រការ ២** : រាល់បទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០១

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ_កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨-០១-១៣៣ ប្រក

# ប្រកាស

## ស្តីពី

## រចនាសម្ព័ន្ធរបស់នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា និង មុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខៈនស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខៈជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- យោងតាមប្រកាសលេខ : ធ៨៩៨-៣៨៥ប្រក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និង មុខងារ-ភារកិច្ចរបស់អង្គភាពក្រោមឱវាទ
- យោងតាមការអនុមតិរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០១

## សំរេច

**ប្រការ ១.-** រៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡានិងកំណត់មុខងារ-ភារកិច្ចរបស់ការិយាល័យនិងផ្នែកនៅក្រោមឱវាទ នៅក្នុងប្រការបន្តបន្ទាប់ដូចខាងក្រោម ។

**ប្រការ ២.-** នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡាស្ថិតនៅក្រោមចំណុះអគ្គបេឡា ហើយមានមុខងារ-ភារកិច្ចចំបងៗ គឺ៖

- ធានាសុវត្ថិភាពដោយផ្ទាល់ចំពោះឃ្លាំងសន្និធិនៃធនប័ត្រត្រៀមបំរុង ឃ្លាំងសន្និធិនៃធនប័ត្រសំរាប់ចរាចរ និង ចំពោះបេឡាប្រូបិយវត្ថុជាតិ រូបិយប័ណ្ណ និង លោហធាតុត្បូងថ្មមានតម្លៃផ្សេងៗទៀត
- សិក្សា និង លើកផែនការបោះពុម្ពធនប័ត្រឬចាក់ពុម្ពកាសប្រាក់ និងកាសមាស ទៅតាមតម្រូវការចាំបាច់
- ចាត់វិធានការសំរបសំរួលបែងចែក និងប្រុងប្រយ័ត្នចំពោះសាច់ប្រាក់នៅក្នុងឃ្លាំងនិងបេឡានៃសាខាធនាគារជាតិខេត្ត-ក្រុង
- អនុវត្តផ្ទាល់ក្នុងចលនាសាច់ប្រាក់ : បញ្ចូល បញ្ចេញពីឃ្លាំង ចំណូលចំណាយប្រចាំថ្ងៃ ស្រាស់ជ្រើសយកក្រដាសប្រាក់ចាស់រហែកបំផ្លាញចោល និងជំនួសដោយក្រដាសប្រាក់ថ្មី ។

នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡាត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

**ប្រការ ៣.-** រចនាសម្ព័ន្ធរបស់នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា ត្រូវបានរៀបចំអោយមានការិយាល័យចំនួន៦នៅក្រោមឱវាទ ដូចមានអង្គការលេខភ្ជាប់ជាឧបសម្ព័ន្ធ គឺ៖

១- ការិយាល័យរដ្ឋបាល គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែករដ្ឋបាល
- ផ្នែកទំនាក់ទំនងការងារ ។

២- ការិយាល័យឃ្លាំង គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកគ្រប់គ្រងឃ្លាំង
- ផ្នែកគណនេយ្យជំនួយឃ្លាំង
- ផ្នែកដឹកជញ្ជូនទុន ។

៣- ការិយាល័យបេឡា គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកប្រាក់រៀល
- ផ្នែករូបិយប័ណ្ណ
- ផ្នែកដូរប្រាក់ ។

៤- ការិយាល័យគណនេយ្យជំនួយបេឡា គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកសេវាផ្ទាល់អតិថិជន
- ផ្នែកអនុវត្តប្រតិបត្តិការអោយសកម្មភាពជំនាញ ។

៥- ការិយាល័យរាប់-ស្រាស់ជ្រើស គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែករាប់

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

- ផ្នែកស្រាល់ជ្រើស
- ផ្នែកបញ្ជីសរុប ។

៦- ការិយាល័យគ្រប់គ្រងសាច់ប្រាក់ ទទួលបន្ទុកលើ :

- ផ្នែកគ្រប់គ្រងសាច់ប្រាក់
- ផ្នែកបំផ្លាញក្រដាសប្រាក់រហែក ។

ការិយាល័យនីមួយៗ ក៏ដូចផ្នែកនីមួយៗដែលនៅក្រោមចំណុះ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

**ប្រការ ៤.-** ការិយាល័យរដ្ឋបាលមានមុខងារ-ភារកិច្ចធានាដំណើរការរលូនរបស់នាយកដ្ឋានទាំងមូល នៅលើវិស័យគ្រប់គ្រងទ្រព្យសម្បត្តិ ជីវភាពមន្ត្រីបុគ្គលិក ការងាររបៀប សណ្តាប់ធ្នាប់និងពិធីការ រួមមានភារកិច្ចលំអិតតាមផ្នែកដូចតទៅ ៖

១ _ ផ្នែករដ្ឋបាល :

- តាក់តែង ចាត់បញ្ជូននិងរក្សាទុក នូវរាល់លិខិតឬឯកសារទាក់ទងផ្ទៃក្នុង ក៏ដូចចេញទៅខាងក្រៅ
- ទទួល បញ្ជូនតាមមុខសញ្ញា និង រក្សាទុក នូវរាល់លិខិតឬឯកសារដែលផ្ញើចូល
- ដោះស្រាយ និង ផ្គត់ផ្គង់សំភារៈ-មធ្យោបាយបំរើការងារ តាមសេចក្តីត្រូវការជាក់ស្តែង
- គ្រប់គ្រងបញ្ជីវត្តមានមន្ត្រីបុគ្គលិក រៀបចំកម្មវិធីការងារសំរាប់ថ្នាក់ដឹកនាំ និង ធានាពិធីការចំពោះភ្ញៀវនិងពិធីផ្សេងៗ
- លើកសំណើអំពីការតម្លើងឋានៈឬអតីតភាព ការដាក់វិន័យ ការលើកសរសើរ ចំពោះមន្ត្រីបុគ្គលិក តាមការជាក់ស្តែង
- ធ្វើកំណត់ហេតុរាល់ពេលប្រជុំថ្នាក់ដឹកនាំ ឬ ពិធីផ្សេងៗ
- គ្រប់គ្រងទ្រព្យសម្បត្តិ និង បញ្ជីសារពើភ័ណ្ឌរបស់នាយកដ្ឋាន
- បូកសរុបការងារក្នុងនាយកដ្ឋាន និង អគ្គបេឡា
- ធ្វើរបាយការណ៍តាមគ្រាកំណត់នីមួយៗ ជូនថ្នាក់ដឹកនាំអគ្គបេឡា និង នាយកដ្ឋានពាក់ព័ន្ធ
- កសាងគំរោងថវិកាប្រចាំគ្រាកំណត់ សំរាប់ទ្រទ្រង់ដំណើរការធនាគារទាំងមូល ។

២ _ ផ្នែកទំនាក់ទំនងការងារ :

- រៀបចំធ្វើទំរង់បែបបទ ដើម្បីធ្វើទំនាក់ទំនងជាមួយអង្គភាពនានា ក្នុងការផ្ញើ-ទទួលលិខិតនិងសារទូរលេខ នៅក្នុងនិងក្រៅប្រទេស
- ធ្វើផែនការចំណាយប្រចាំខែ ឆ្នាំ របស់នាយកដ្ឋាន
- ធ្វើគំរោង និង ស្នើសុំប្រាក់ឧបត្ថម្ភផ្សេងៗ
- ទទួលសំណើពីគ្រប់ការិយាល័យ ដើម្បីស្នើសុំយោបល់ពីថ្នាក់ដឹកនាំ
- គ្រប់គ្រងកំលាំងពលកម្មក្នុងនិងក្រៅម៉ោងធ្វើការ ។

**ប្រការ ៥._** ការិយាល័យឃ្លាំងមានមុខងារ-ភារកិច្ចអនុវត្តការគ្រប់គ្រង និង ថែរក្សាការពារឃ្លាំងប្រាក់របស់ធនាគារជាតិនៃកម្ពុជា រួមមានភារកិច្ចលំអិតតាមផ្នែកដូចតទៅ ៖

១ _ ផ្នែកគ្រប់គ្រងឃ្លាំង :

- ពិនិត្យសំណល់ឃ្លាំងជាសាច់ប្រាក់ ប្រៀបធៀបនឹងជើងលេខក្នុងសៀវភៅបញ្ជី ជាប្រចាំតាមគ្រាកំណត់
- ថែរក្សាការពារសុវត្ថិភាពនៃឃ្លាំងនានានិងធ្វើពលកម្មបោសសំអាតជាប្រចាំ
- បែងចែកប្រភេទក្រដាសប្រាក់ដែលត្រូវបោះផ្សាយ
- រៀបចំទុកដាក់ក្រដាសប្រាក់តាមប្រភេទ និង តាមបន្ទប់ឃ្លាំងនីមួយៗដោយឡែក ។

២ _ ផ្នែកគណនេយ្យជំនួយឃ្លាំង :

- កាន់សាលាកប័ត្រសន្និធិឬសៀវភៅបញ្ជី ដើម្បីកត់ត្រាតាមដានអោយបានច្បាស់លាស់ ត្រឹមត្រូវ គ្រប់គ្រាន់និងទាន់ពេលវេលាអំពីសកម្មភាពបញ្ចេញ-បញ្ចូលកាសនិងក្រដាសប្រាក់ រូបិយប័ណ្ណនិងទ្រព្យសម្បត្តិមានតម្លៃ
-ចាត់ចែងរាប់ពិនិត្យសាច់ប្រាក់ បញ្ចេញ-បញ្ចូលឃ្លាំងជាមួយការិយាល័យបេឡា និង ការិយាល័យរាប់-ស្រាល់ជ្រើស
- កត់ត្រាតាមដានសកម្មភាព បញ្ចេញ-បញ្ចូលរបស់ឃ្លាំងត្រៀមបំរុងនិងឃ្លាំងសំរបសំរួលបោះផ្សាយ
- កត់ត្រាតាមដានប្រាក់រហែករិចរិលដែលត្រៀមកាត់កំទេចនិងប្រាក់ដែលបានដុតរួចហើយ
- ធ្វើរបាយការណ៍ពីស្ថិតិសាច់ប្រាក់ សំណល់សាច់ប្រាក់រៀលនិងរូបិយប័ណ្ណរបស់ឃ្លាំង ប្រចាំថ្ងៃ សប្តាហ៍ ខែ ត្រីមាស ។

៣ _ ផ្នែកដឹកជញ្ជូនទុន :

- លើកផែនការបញ្ចេញ-បញ្ចូលនិងដឹកជញ្ជូនសាច់ប្រាក់ ដើម្បីដាក់ជូនថ្នាក់លើពិនិត្យនិងសំរេច
- ចាត់ចែងរៀបចំសាច់ប្រាក់ផ្តល់អោយសាខាធនាគារជាតិនៃកម្ពុជា ឬដឹកត្រឡប់មកកាន់ធនាគារជាតិនៃកម្ពុជាវិញ
- តាមដានការរាប់សាច់ប្រាក់ដែលដឹកមកពីសាខាធនាគារជាតិនៃកម្ពុជានានា
- ធានាសុវត្ថិភាពក្នុងការដឹកជញ្ជូន ដោយសហការជាមួយកងសន្តិសុខ ។

**ប្រការ ៦.-** ការិយាល័យបេឡាមានមុខងារ-ភារកិច្ចអនុវត្តការចំណូល-ចំណាយសាច់ប្រាក់រវាងធនាគារជាតិនៃកម្ពុជានិងបណ្តាអង្គភាព អង្គការផ្សេងៗ និង អតិថិជនរួមមានភារកិច្ចលំអិតតាមផ្នែកដូចតទៅ ៖

១ _ ផ្នែកប្រាក់រៀល :

- អនុវត្តការទទួលចំណូលឬចំណាយសាច់ប្រាក់រៀល តាមមូលប្បទានប័ត្រឬប័ណ្ណចំណូល-ចំណាយពីនាយកដ្ឋានជំនាញនានា របស់ធនាគារជាតិនៃកម្ពុជា
- សុំបញ្ចេញសាច់ប្រាក់បន្ថែមឬសុំបញ្ចូលឃ្លាំងសំរបសំរួលបោះផ្សាយវិញ ដើម្បីធានាតុល្យភាពចំណូល-ចំណាយសាច់ប្រាក់ប្រចាំថ្ងៃ ព្រមទាំងសំណូមពរចាំបាច់សំរាប់តម្រូវការតាមរចនាសម្ព័ន្ធនៃប្រភេទប្រាក់របស់ទីផ្សារ
- រៀបចំការបិទបេឡាប្រចាំថ្ងៃ ដោយផ្ទៀងផ្ទាត់សំណល់សាច់ប្រាក់អោយត្រូវជាមួយនឹងសៀវភៅបេឡា បញ្ជីតាមដានប្រភេទប្រាក់ និង បញ្ជីគណនេយ្យជំនួយ ហើយរៀបចំរក្សាទុកដាក់ ដោយធានាសុវត្ថិភាព ។

២ _ ផ្នែករូបិយប័ណ្ណ :

- អនុវត្តការទទួលចំណូលឬចំណាយសាច់ប្រាក់រូបិយប័ណ្ណ តាមមូលប្បទានប័ត្រឬប័ណ្ណចំណូល-ចំណាយពីគ្រប់នាយកដ្ឋានជំនាញរបស់ធនាគារជាតិនៃកម្ពុជា
- សុំបញ្ចេញបន្ថែមឬសុំបញ្ចូលឃ្លាំងរូបិយប័ណ្ណ នូវសាច់ប្រាក់រូបិយប័ណ្ណ ដើម្បីធានាតុល្យភាពចំណូល-ចំណាយក្នុងថ្ងៃ
- រៀបចំការបិទបេឡារូបិយប័ណ្ណប្រចាំថ្ងៃ ដោយផ្ទៀងផ្ទាត់សំណល់សាច់ប្រាក់អោយត្រូវជាមួយនឹងសៀវភៅបេឡា បញ្ជីតាមដានប្រភេទប្រាក់ និងបញ្ជីគណនេយ្យជំនួយ ហើយរៀបចំរក្សាទុកដាក់ ដោយធានាសុវត្ថិភាព ។

៣ _ ផ្នែកប្តូរប្រាក់ :

- រៀបចំនិងគ្រប់គ្រងការប្តូរប្រាក់ចាស់រហែកប្រភេទមានតម្លៃ តូច ធំ តាមភាពជាក់ស្តែង
- សហការជាមួយការិយាល័យរាប់-ស្រាល់ជ្រើស ក្នុងការទទួលប្រាក់ពីអតិថិជនដែលមានចំនួនសាច់ប្រាក់ច្រើន
- បែងចែកប្រាក់រៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗជូនគ្រប់នាយកដ្ឋានតាមឯកសារបែបបទដែលមានការពិនិត្យនិងសំរេចអនុម័តត្រឹមត្រូវនិងច្បាស់លាស់
- រៀបចំធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំ ។

**ប្រការ ៧.–** ការិយាល័យគណនេយ្យជំនួយបេឡាមានមុខងារ-ភារកិច្ចបង្កើតសក្ខីប័ត្រគ្រប់ប្រភេទ តាមវិធានគណនេយ្យជំនួយ ដើម្បីបង្គុលក្ខណៈអោយរាល់ប្រតិបត្តិការជាសាច់ប្រាក់រៀលនិងរូបិយប័ណ្ណ ពីនាយកដ្ឋានជំនាញទាំងអស់ អាចអនុវត្តបានដោយប្រសិទ្ធិភាពនិងសុវត្ថិភាព រួមមានភារកិច្ចលំអិតតាមផ្នែកដូចតទៅ៖

១ _ ផ្នែកសេវាផ្ទាល់អតិថិជន :

- ធ្វើប័ណ្ណបង់ប្រាក់និងប័ណ្ណបើកប្រាក់ជូនអតិថិជនរួមមាន ក្រសួងស្ថាប័នគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តុប្តូរប្រាក់ សាខាធនាគារជាតិនៃកម្ពុជាអគ្គបេឡា រតនាគារជាតិ និង នាយកដ្ឋានពាក់ព័ន្ធ ដោយផ្អែកលើមូលប្បទានប័ត្រអាណត្តិចំណាយ ឬ ឯកសារផ្សេងទៀតដែលមានតម្លៃអោយអនុវត្តបាន
- គ្រប់គ្រង និងរៀបចំទុកដាក់សំភារៈនិងឯកសារផ្សេងៗ ដែលមាននៅក្នុងការិយាល័យ ។

២ _ ផ្នែកអនុវត្តប្រតិបត្តិការអោយសកម្មភាពជំនាញ :

- រៀបចំសក្ខីប័ត្រនៃប្រតិបត្តិការសាច់ប្រាក់រៀលនិងរូបិយប័ណ្ណ ក្នុងក្របខ័ណ្ឌឯកសារគណនេយ្យជាទូទៅ(GAD) និង ឯកសារគណនេយ្យរវាងធនាគារជាតិនៃកម្ពុជា និង សាខាធនាគារជាតិនៃកម្ពុជា(NAD)
- រៀបចំនិងផ្ទៀងផ្ទាត់ឡើងវិញ រវាងសក្ខីប័ត្រនិងទិន្នានុលេខបេឡាក្នុងប្រតិបត្តិការប្រចាំថ្ងៃ
- ធ្វើការបូកសរុបសក្ខីប័ត្រផ្នែកGAD និងNAD ខាងឥណពន្ធអោយស្មើខាងឥណទាន ហើយប្រមូលផ្តុំជាសំណុំឯកសារ(Batch) សំរាប់ផ្នែកនីមួយៗនេះ ដើម្បីបញ្ជូនទៅនាយកដ្ឋានគណនេយ្យនិងនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀត តាមគោលការណ៍កំណត់ ។

**ប្រការ ៨.–** ការិយាល័យរាប់-ស្រាល់ជ្រើសមានមុខងារ-ភារកិច្ចអនុវត្តការរាប់ និង ស្រាល់ជ្រើសក្រដាសប្រាក់-កាស ដែលការិយាល័យបេឡាបានទទួលចំណូលពីអតិថិជន និងអង្គភាពនានា ហើយបានបញ្ជូនមកប្រគល់អោយ រួមមានភារកិច្ចលំអិតតាមផ្នែកដូចតទៅ ៖

១ _ ផ្នែករាប់ប្រាក់ :

- ទទួលកាស និង ក្រដាសប្រាក់ពីការិយាល័យបេឡាមករាប់ ពិនិត្យ
- រាប់ពិនិត្យចំនួនសន្លឹក ក្រដាសប្រាក់សេរីថ្មី និង ក្រដាសប្រាក់សេរីចាស់និងចំនួនកាស ដោយដាក់ដោយឡែកពីគ្នា តាមប្រភេទនីមួយៗ
- ធ្វើកំណត់ហេតុដកហូតពីអតិថិជននូវក្រដាសប្រាក់ក្លែងក្លាយនិងប្រាក់គំរូ (Specimen) ដែលអតិថិជនយកមកបង់ ដើម្បីបញ្ជូនទៅធ្វើការកាត់កំទេចនិងដុតបំផ្លាញចោល
- ប្រគល់ប្រាក់ដែលរាប់ ពិនិត្យត្រឹមត្រូវរួចហើយ នៅរាល់ចុងម៉ោងនៃថ្ងៃធ្វើការ អោយទៅការិយាល័យឃ្លាំង ។

២ _ ផ្នែកស្រាល់ជ្រើស :

- ទទួលសាច់ប្រាក់ពីការិយាល័យឃ្លាំង មកធ្វើការស្រាល់ជ្រើស
- ជ្រើសរើសក្រដាសប្រាក់ចាស់-រហែក សឹករិចរិលមិនគ្រប់លក្ខណៈ ដើម្បីត្រៀមបំផ្លាញចោល
- ជ្រើសរើសប្រាក់ល្អ ដាក់ដោយឡែកដើម្បីបញ្ចេញទៅចរាចរណ៍វិញ
- រាប់ ពិនិត្យដកចេញនូវក្រដាសប្រាក់គំរូនិងប្រាក់ក្លែងក្លាយ ដាក់ដោយឡែក ដើម្បីធ្វើកំណត់ហេតុបញ្ជូនទៅការិយាល័យគ្រប់គ្រងសាច់ប្រាក់
- រាប់ ពិនិត្យ និង ស្រាល់ជ្រើសទាំងប្រាក់ល្អ និងចាស់រហែកអោយបានត្រឹមត្រូវ រួចហើយប្រគល់ទៅអោយការិយាល័យឃ្លាំងវិញ
- តាមដានអាយុកាលចរាចរណ៍នៃក្រដាសប្រាក់គ្រប់ប្រភេទ ។

៣ _ ផ្នែកបញ្ជីសរុប :

- ត្រួតពិនិត្យនិងគ្រប់គ្រងក្រដាសប្រាក់-កាសពុំទាន់រាប់ និង ក្រដាសប្រាក់-កាសដែលមិនទាន់គ្រប់តាមចំនួនបាច់-ដុំ-កញ្ចប់ ដែលកំណត់ត្រូវបញ្ចូលឃ្លាំងប្រចាំថ្ងៃ
- សរុបបិទបញ្ជីចុងថ្ងៃជាប្រចាំអោយបានគ្រប់គ្រាន់ត្រឹមត្រូវ ផ្ញើជូនការិយាល័យគណនេយ្យជំនួយបេឡា
- ធ្វើរបាយការណ៍ពីសកម្មភាពការងារ តាមគ្រាកំណត់ជូនថ្នាក់ដឹកនាំនាយកដ្ឋាន
- ជួសជុលម៉ាស៊ីនរាប់ប្រាក់និងគ្រប់គ្រងសំភារៈក្នុងការិយាល័យ ។

**ប្រការ ៩._** ការិយាល័យគ្រប់គ្រងសាច់ប្រាក់មានមុខងារ-ភារកិច្ចអនុវត្តការងារដែលទាក់ទងទៅនឹងការតាមដានសាច់ប្រាក់គ្រប់ប្រភេទក្នុងចរាចរណ៍និងសំណល់សាច់ប្រាក់របស់សាខាធនាគារជាតិខេត្ត-ក្រុង រួមមានភារកិច្ចលំអិតតាមផ្នែកដូចតទៅ៖

១ _ ផ្នែកគ្រប់គ្រងសាច់ប្រាក់ :

- ពិនិត្យការសុំប្តូរប្រាក់រហែករបស់អតិថិជន ហើយដាក់ជូនគណៈកម្មការផ្ទៃក្នុងសំរេច
- ពិនិត្យនិងតាមដានប្រាក់រហែក និងប្រាក់ក្លែងក្លាយ ហើយផ្ទៀងផ្ទាត់ជាមួយសាច់ប្រាក់ជាក់ស្តែងដែលរក្សាទុកក្នុងឃ្លាំង
- ទទួលនិងរាប់ពិនិត្យក្រដាសប្រាក់មិនគ្រប់លក្ខណៈគ្រប់ប្រភេទ ដែលការិយាល័យរាប់ និង ស្រាស់ជ្រើសប្រគល់អោយ
- បូកសរុបរបាយការណ៍ តាមគ្រាកំណត់ ។

២ _ ផ្នែកបំផ្លាញក្រដាសប្រាក់រហែក :

- រៀបចំទំរង់បែបបទនិងបំពេញការងារចាំបាច់មួយចំនួន ជូនគណៈកម្មការកាត់កំទេច និង ដុតបំផ្លាញក្រដាសប្រាក់រហែករិចរិល
- គ្រប់គ្រងបន្ទប់ម៉ាស៊ីនកាត់កំទេច និងរក្សាទុកគង់វង្សនូវឯកសារដែលពាក់ព័ន្ធ ។

**ប្រការ ១០._** ក្រៅពីភារកិច្ចដែលមានចែងនៅរាល់ប្រការខាងលើនេះ ថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និង ផ្នែកនីមួយៗ ត្រូវអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់លើប្រគល់ជូន ។

**ប្រការ ១១._** ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីបុគ្គលិកនាយកដ្ឋានបោះផ្សាយ-ឃ្លាំងបេឡា ត្រូវរក្សាដាច់ខាតនូវការសម្ងាត់វិជ្ជាជីវៈ អនុលោមតាមមាត្រា១៦និងមាត្រា៧១នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា។

**ប្រការ ១២._** រាល់ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៣.-** អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងនាយកដ្ឋានសាមី ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១៤.-** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១

ទេសាភិបាល

ជា ចាន់តូ

**<u>កន្លែងទទួល</u> :**

- ដូចប្រការ១៣
  " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

---

**ចម្លងជូន :**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាពត៌មាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធលេខ
# ស្តីពី
# មុខងារ-ភារកិច្ចរបស់នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា

(ឧបសម្ព័ន្ធនៃប្រកាសលេខ : ធ៨០១-...១៣៣..... ប្រក ចុះថ្ងៃទី..០៤....ខែ..តុលា....ឆ្នាំ ២០០១)



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨-០១-១៣៤ប្រក

# ប្រកាស

## ស្តីពី

## រចនាសម្ព័ន្ធរបស់នាយកដ្ឋានរោងពុម្ព និង មុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខៈនស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខៈជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- យោងតាមប្រកាសលេខ : ធ៨៩៨-៣៨៥ប្រក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និង មុខងារ-ភារកិច្ចរបស់អង្គភាពក្រោមឱវាទ
- យោងតាមការអនុមតិរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០១

## សំរេច

**ប្រការ ១.-** រៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋានរោងពុម្ព និង កំណត់មុខងារ-ភារកិច្ចរបស់ការិយាល័យនិងផ្នែកនៅក្រោមឱវាទ នៅក្នុងប្រការបន្តបន្ទាប់ខាងក្រោម ។

**ប្រការ ២.-** នាយកដ្ឋានរោងពុម្ពស្ថិតនៅក្រោមចំណុះអគ្គបេឡា ហើយមានមុខងារ-ភារកិច្ចចំបងៗ គឺ ៖

- គ្រប់គ្រងរោងពុម្ពរបស់ធនាគារជាតិនៃកម្ពុជា ដោយដឹកនាំអនុវត្តផ្ទាល់នូវផែនការបោះពុម្ពធនប័ត្រ លិខិតស្នាមមានតម្លៃគ្រប់ប្រភេទសំរាប់ស្ថាប័នផ្ទាល់ ឬតាមការបញ្ជាទិញឬផ្តល់សេវាពីខាងក្រៅ
- គ្រប់គ្រងល្អទាំងបរិមាណ ទាំងគុណភាព នូវប្រព័ន្ធម៉ាស៊ីនបោះពុម្ព សម្ភារៈបច្ចេកទេស និងសន្និធិក្រដាសពិសេសសំរាប់បោះពុម្ព
- ធានាប្រសិទ្ធភាព និងគុណភាពខ្ពស់នៃផលិតកម្មក្នុងរោងពុម្ព
- ចាត់ចែងកម្លាំងពលកម្មក្នុងខ្សែសង្វាក់ផលិតកម្ម ដោយលើកកំពស់វិធានការប្រុងប្រយ័ត្នប្រឆាំងចំពោះការបាត់បង់ធនប័ត្រដែលបោះពុម្ពរួច ។

នាយកដ្ឋានរោងពុម្ពត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយ ឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

**ប្រការ ៣.-** រចនាសម្ព័ន្ធរបស់នាយកដ្ឋានរោងពុម្ពត្រូវបានរៀបចំអោយមានការិយាល័យ៣នៅក្រោមឱវាទ ដូចមានរង្គការលេខភ្ជាប់ជាឧបសម្ព័ន្ធ គឺៈ

១- ការិយាល័យរដ្ឋបាល ផែនការ និងគណនេយ្យជំនួយរោងពុម្ព គ្រប់គ្រងផ្ទាល់នូវៈ
- ផ្នែករដ្ឋបាល
- ផ្នែកផែនការ
- ផ្នែកឃ្លាំងនិងគណនេយ្យជំនួយរោងពុម្ព ។

២- ការិយាល័យផលិតកម្ម គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកកសាងពុម្ព
- ផ្នែកបោះពុម្ព
- ផ្នែកបោះលេខ ។

៣- ការិយាល័យពិនិត្យ-ជ្រើសរាប់ គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកពិនិត្យគុណភាព-រាប់
- ផ្នែកកាត់
- ផ្នែកជ្រើសរាប់
- ផ្នែកវេចខ្ចប់ ។

ការិយាល័យនីមួយៗ ក៏ដូចផ្នែកនីមួយៗដែលនៅក្រោមចំណុះ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

**ប្រការ ៤.-** ការិយាល័យរដ្ឋបាល ផែនការនិងគណនេយ្យជំនួយរោងពុម្ពមានមុខងារ-ភារកិច្ចអនុវត្តការងារដែលទាក់ទងទៅនឹងកិច្ចការរដ្ឋបាល ផែនការអភិវឌ្ឍន៍ផលិតកម្មនិងគណនេយ្យជំនួយរោងពុម្ព ចំពោះសម្ភារៈនិងផលិតផលទាំងអស់របស់រោងពុម្ពរួមមានភារកិច្ចតាមផ្នែកដូចតទៅ ៖

១ _ ផ្នែករដ្ឋបាល :

- តាក់តែង ចាត់បញ្ជូននិងរក្សាទុក នូវរាល់លិខិតឬឯកសារទាក់ទងផ្ទៃក្នុងក៏ដូចចេញទៅខាងក្រៅ
- ទទួល បញ្ជូនតាមមុខសញ្ញា និង រក្សាទុក នូវរាល់លិខិតឬឯកសារដែលផ្ញើចូល
- ដោះស្រាយ និង ផ្គត់ផ្គង់សំភារៈ-មធ្យោបាយបំរើការងារ តាមសេចក្តីត្រូវការជាក់ស្តែង
- គ្រប់គ្រងទ្រព្យសម្បត្តិ និង របៀបការពើភ័ណ្ឌរបស់នាយកដ្ឋាន
- គ្រប់គ្រងបញ្ជីវត្តមានមន្ត្រីបុគ្គលិក រៀបចំកម្មវិធីការងារសំរាប់ថ្នាក់ដឹកនាំ និង ធានាពិធីការចំពោះភ្ញៀវនិងពិធីផ្សេងៗ
- លើកសំណើអំពីការតម្លើងឋានៈឬអតីតភាព ការដាក់វិន័យ ការលើកសរសើរចំពោះមន្ត្រីបុគ្គលិក តាមការជាក់ស្តែង
- កសាងគំរោងថវិកាប្រចាំគ្រាកំណត់ សំរាប់ទ្រទ្រង់ដំណើរការរោងពុម្ពធនាគារជាតិទាំងមូល ។

២ _ ផ្នែកផែនការ :

- លើកគំរោងជូនថ្នាក់ដឹកនាំ អំពីផែនការផលិតកម្មអាជីវកម្មរបស់រោងពុម្ពប្រចាំគ្រា
- បង្កើតគំរូធនប័ត្រត្រៀមបំរុងសំរាប់ពេលអនាគត
- កសាងគំរោងអំពីតម្រូវការសំភារៈបរិក្ខារ គ្រឿងម៉ាស៊ីន និង កំលាំងពលកម្ម តាមដំណាក់កាលនីមួយៗ
- កសាងផែនការអភិវឌ្ឍន៍ផលិតកម្មអាជីវកម្មរបស់រោងពុម្ព
- ចាត់ចែងកំលាំងពលកម្ម និងរៀបចំកម្មវិធីផលិតកម្ម ដើម្បីអនុវត្តអោយបានសំរេចតាមផែនការ ។

៣ _ ផ្នែកឃ្លាំងនិងគណនេយ្យជំនួយរោងពុម្ព :

- គ្រប់គ្រងនិងកាន់កាប់គណនេយ្យជំនួយ ( គណនេយ្យសម្ភារៈ ) ចំពោះឃ្លាំង៣ គឺឃ្លាំងក្រដាស ឃ្លាំងផលិតផលសំរេចនិងឃ្លាំងផលិតផលមិនគ្រប់លក្ខណៈ

- គ្រប់គ្រងសម្ភារៈបរិក្ខារ សំរាប់ផ្គត់ផ្គង់អោយផ្នែកផលិតកម្មនានា
- រៀបចំគំរោងចំណាយនៃផលិតកម្ម តាមគ្រាកំណត់ ដើម្បីដាក់ជូនសុំការអនុម័តពីថ្នាក់លើ
- រៀបចំប័ណ្ណបញ្ចេញ-បញ្ចូលឃ្លាំង និងបង្កើតសក្ខីប័ត្រសំរាប់គណនេយ្យជំនួយ ក្នុងការប្រគល់-ទទួលក្រដាសពិសេស ផលិតផលសំរេច និងផលិតផលមិនគ្រប់លក្ខណៈ ។

**ប្រការ ៥.–** ការិយាល័យផលិតកម្មមានមុខងារ-ភារកិច្ចអនុវត្តផែនការផលិតកម្ម បោះពុម្ពធនប័ត្រ បោះពុម្ពឯកសារមានតម្លៃផ្សេងៗ និង គ្រប់គ្រងល្អផលិតផលសំរេច ពាក់កណ្តាលសំរេច គ្រឿងម៉ាស៊ីន និង សម្ភារៈបរិក្ខារផលិតកម្ម រួមមានភារកិច្ចតាមផ្នែកដូចតទៅ ៖

១ _ ផ្នែកកសាងពុម្ព :

- ចាត់តាំងការកសាងសំភារៈដើម ហ្វីលរូបភាព កសាងពុម្ពនិងបន្ទះពុម្ពប្រកបអោយគុណភាពខ្ពស់ ផ្គត់ផ្គង់ផ្នែកបោះពុម្ព ផ្អែកតាមផែនការរបស់ថ្នាក់លើ
- គ្រប់គ្រងដោយហ្មត់ចត់បំផុតនូវសំភារៈដើម ហ្វីលរូបភាពគ្រប់ប្រភេទព្រមទាំងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការងារបោះពុម្ពធនប័ត្រ
- ថែទាំគ្រឿងម៉ាស៊ីន និងឧបករណ៍ផលិតកម្មក្នុងផ្នែកសោងពុម្ព ជូតសំអាតជាប្រចាំ និង ប្តូរខ្ចាញ់-ដាក់ប្រេង ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។

២ _ ផ្នែកបោះពុម្ព :

- ចាត់តាំងការរាប់ទទួលក្រដាសពិសេសពីផ្នែកគ្រប់គ្រងឃ្លាំងអោយបានប្រាកដប្រជាគ្រប់ចំនួន តាមផែនការនៃវគ្គនីមួយៗ
- ដំណើរការបោះពុម្ពធនប័ត្រប្រកបដោយគុណភាពខ្ពស់ តាមប្រភេទ និងតាមគំរូ ដែលថ្នាក់លើបានប្រគល់អោយ
- ដំណើរការបោះពុម្ពលិខិតស្នាមមានតម្លៃផ្សេងៗ និងមុខសញ្ញាបោះពុម្ពដទៃទៀត តាមផែនការរបស់ថ្នាក់លើ
- គ្រប់គ្រងល្អឃ្លាំងផលិតផលកំពុងបោះពុម្ព និង ឃ្លាំងសម្ភារៈបច្ចេកទេសបោះពុម្ព ព្រមទាំងបន្ទះពុម្ព ទឹកខ្មៅបោះពុម្ព ប្រកបដោយនិរភ័យដាច់ខាត
- ថែទាំគ្រឿងម៉ាស៊ីននិងឧបករណ៍ផលិតកម្មផ្សេងៗទៀត ជូតសំអាតជាប្រចាំ និងប្តូរខ្ចាញ់-ដាក់ប្រេង ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។

៣ _ ផ្នែកបោះលេខ :

- គ្រប់គ្រងម៉ាស៊ីនបោះពុម្ពលេខមាលា
- ប្រើប្រាស់និងថែទាំត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ចាត់ចែងការបោះពុម្ពលេខមាលានៅលើធនប័ត្រគ្រប់តំរូវ ផ្អែកតាមលំដាប់លេខមាលាដែលបានយល់ព្រមពីថ្នាក់លើតាមវត្ថុនីមួយៗ ។

**ប្រការ ៦._** ការិយាល័យពិនិត្យ-ជ្រើសរាប់មានមុខងារ-ភារកិច្ចពិនិត្យគុណភាព រាប់ផ្ទៀងផ្ទាត់ឡើងវិញ កាត់ ជ្រើសរាប់និងវេចខ្ចប់ នូវធនប័ត្រដែលបានបោះពុម្ពរួច អោយទៅជាផលិតផលសំរេចជាស្ថាពរ រួមមានភារកិច្ចតាមផ្នែកដូចតទៅ ៖

១ _ ផ្នែកពិនិត្យគុណភាព-រាប់ :

- ពិនិត្យពិច័យដោយយកចិត្តទុកដាក់ ចំពោះផលិតផលបោះពុម្ពរួចហើយ ជាសន្លឹកធំ ដោយប្រៀបធៀបជាមួយនឹងក្រដាសប្រាក់គំរូ ហើយគូសចំណាំនូវរាល់កំហុសឆ្គងអំពីពណ៌ រូបភាព ឬ លេខ-មាលា
- រាប់ពិនិត្យដោយម៉ាស៊ីន ចំពោះផលិតផលដែលបានត្រួតពិនិត្យរួចហើយ ដើម្បីត្រៀមប្រគល់ទៅកាត់ជាសន្លឹកតូច
- គ្រប់គ្រងល្អឃ្លាំងផលិតផលកំពុងពិនិត្យគុណភាព
- ជូតសំអាតជាប្រចាំ និង ថែទាំតាមលក្ខណៈបច្ចេកទេស ចំពោះម៉ាស៊ីនរាប់សន្លឹកធំដែលឋិតក្នុងបន្ទុករបស់ខ្លួន ។

២ _ ផ្នែកកាត់ :

- ទទួលយកផលិតផលសន្លឹកធំដែលបានពិនិត្យគុណភាព និង រាប់រួចហើយពីផ្នែកពិនិត្យគុណភាព-រាប់ ដំណើរការកាត់ជាសន្លឹកតូច តាមទំហំ និងខ្នាតដែលបានកំណត់
- រៀបចំផលិតផលដែលកាត់រួចហើយបញ្ចូលកែសត្រឹមត្រូវតាមរបៀបរបបដែលថ្នាក់លើបានកំណត់
- ប្រគល់ភ្លាមក្នុងថ្ងៃ នូវផលិតផលដែលបានកាត់រួចហើយ ទៅអោយផ្នែកជ្រើសរាប់-វេចខ្ចប់
- ថែទាំជូតសំអាតម៉ាស៊ីនកាត់ជាប្រចាំនិងបូមខ្លាញ់-ដាក់ប្រេង ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។

៣ _ ផ្នែកជ្រើសរាប់ :

- ចាត់តាំងការជ្រើសយកផលិតផលមិនគ្រប់លក្ខណៈ ដែលផ្នែកពិនិត្យគុណភាព-រាប់ បានគូសចំណាំដោយប៊ិចហ្វឺត ចេញពីដុំប្រាក់ដែលផ្នែកកាត់បាន

កាត់រួចហើយបញ្ជូនមក ហើយបញ្ចូលបង្គ្រប់វិញ ដោយផលិតផលជាមាលាត្រៀម

- រៀបចំផលិតផលដែលបានជ្រើសរាប់រួចហើយជាថ្នាប់(១០០សន្លឹក) ជាដុំតាមរបបកំណត់
- រាប់ត្រួតពិនិត្យដុំប្រាក់នីមួយៗ អោយគ្រប់១.០០០សន្លឹក
- បាត់តាំងការចងដុំប្រាក់ដោយម៉ាស៊ីន រួចខ្ចប់ជាដុំនិងបិតផ្លាកសំគាល់ (Etiquettes)
- គ្រប់គ្រងល្អឃ្លាំងផលិតផលកំពុងជ្រើស រាប់ វេចខ្ចប់
- ជូតសំអាតនិងថែទាំម៉ាស៊ីនរាប់ ម៉ាស៊ីនចងនិងសម្ភារៈធ្វើការផ្សេងៗទៀត
- កត់ត្រា តាមដានលទ្ធផលជ្រើស រាប់ប្រចាំថ្ងៃ និងបូកសរុបរាយការណ៍ជូនថ្នាក់លើ អោយបានទៀងទាត់ ។

៤ _ ផ្នែកវេចខ្ចប់ :

- ទទួលយកដុំប្រាក់ពីផ្នែកជ្រើស-រាប់ មកខ្ចប់ជាកញ្ចប់ រួចប្រកបាវនិងផ្ទុំបេ តាមរបៀបរបបដែលបានកំណត់
- បិទផ្លាកសំគាល់លើកញ្ចប់និងបាវផ្ទុំបេ
- រៀបចំកញ្ចប់និងបាវផ្ទុំបេដាក់លើបាឡែត ហើយបញ្ចូលឃ្លាំងគ្រប់គ្រងទុកតាមរបបកំណត់

**ប្រការ ៧.**_ ក្រៅពីភារកិច្ចដែលមានចែងនៅរាល់ប្រការខាងលើនេះ ថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និង ផ្នែកនីមួយៗ ត្រូវអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់លើប្រគល់ជូន ។

**ប្រការ ៨.**_ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រី បុគ្គលិកនាយកដ្ឋានរោងពុម្ព ត្រូវរក្សាដាច់ខាតនូវការសម្ងាត់វិជ្ជាជីវៈ អនុលោមតាមមាត្រា១៦ និងមាត្រា៧១នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៩.**_ រាល់ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១០.-** អគ្គបេឡា អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងនាយកដ្ឋានសាមីត្រូវ អនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១១.-** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០១

**ទេសាភិបាល**

**ជា ចាន់តូ**

**កន្លែងទទួល :**

- ដូចប្រការ១០
- " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន :**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាពត៌មាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានរោងពុម្ព

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធលេខ**
**ស្តីពី**
**មុខងារ-ភារកិច្ចរបស់នាយកដ្ឋានរោងពុម្ព**

(ឧបសម្ព័ន្ធនៃប្រកាសលេខ : ធ៨០១-.......១៣៤៨. ប្រក ចុះថ្ងៃទី...០៤....ខែ..តុលា...ឆ្នាំ ២០០១)




៥៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៨០១-១៣៥ ប្រក

# ប្រកាស

## ស្តីពី

## គោលការណ៍សមាហរណកម្មមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ទៅក្នុងក្របខ័ណ្ឌថ្មី

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខៈនស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខៈជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខៈធ៨៩៩-១២៤ប្រក លេខៈធ៨៩៩-១២៣ប្រក លេខៈ៨៩៩-១២២ប្រក និងលេខៈធ៨៩៩-១២៥ប្រក ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ មន្ត្រីក្រមការ លេខាធិការ និង ភ្នាក់ងារ ធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខៈធ៨៩៩-១៣២ប្រក ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការសមាហរណកម្មមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា
- យោងតាមការអនុមតិរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០១

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់គោលការណ៍សំរាប់ធ្វើសមាហរណកម្មមន្ត្រីបុគ្គលិក ក្នុងក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជាបច្ចុប្បន្ន ដែលកំពុងកាន់មុខតំណែង និង មុខងារពិតប្រាកដ នៅទីស្នាក់ការកណ្តាលនិងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង ដើម្បីផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មី ស្របតាមលក្ខន្តិកៈដោយឡែករបស់ក្របខ័ណ្ឌនីមួយៗ ។

## ជំពូកទី២
## គោលការណ៍សមាហរណកម្មតាមមុខតំណែង

**ប្រការ២.-**

មន្ត្រីដែលត្រូវធ្វើសមាហរណកម្មបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ គឺមន្ត្រីទាំងឡាយដែលកំពុងកាន់មុខតំណែងពិតប្រាកដនៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា មាន ÷

ក/-ឋានន្តរស័ក្តិឧត្តមមន្ត្រី :

- អគ្គលេខាធិការ អគ្គពិនិត្យ អគ្គនាយក អគ្គបេឡា
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា

ខ/-ឋានន្តរស័ក្តិវរៈមន្ត្រី :

- អគ្គលេខាធិការរង អគ្គពិនិត្យរង អគ្គនាយករង អគ្គបេឡារង
- ឧបការីទេសាភិបាល
- ប្រធាននាយកដ្ឋាន
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា

គ/- ឋានន្តរស័ក្តិអនុមន្ត្រី :

- អនុប្រធាននាយកដ្ឋាន
- នាយកសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា ។

## ប្រការ៣.-

ការផ្ទេរមន្ត្រីបញ្ចូលទៅក្នុងថ្នាក់នៃឋានន្តរស័ក្តិនីមួយៗរបស់ក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ត្រូវគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី១នៃប្រកាសនេះ ។

## ប្រការ៤.-

មន្ត្រីដែលត្រូវធ្វើសមាហរណកម្មបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ គឺមន្ត្រីទាំងឡាយដែលកំពុងកាន់មុខតំណែងពិតប្រាកដនៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា មាន ÷

ក/-ឋានន្តរស័ក្តិនាយក្រមការ :

- ប្រធានការិយាល័យ នៅទីស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា
- នាយករងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា

ខ/-ឋានន្តរស័ក្តិក្របការដើមខ្សែ :

- អនុប្រធានការិយាល័យនៅទីស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា
- ប្រធានការិយាល័យនៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា ។

## ប្រការ៥.-

ការផ្ទេរមន្ត្រីបញ្ចូលទៅក្នុងថ្នាក់នៃឋានន្តរស័ក្តិនីមួយៗរបស់ក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២នៃប្រកាសនេះ ។

## ប្រការ៦.-

មន្ត្រីដែលត្រូវធ្វើសមាហរណកម្មបញ្ចូលទៅក្នុងក្របខ័ណ្ឌលេខាធិការ គឺមន្ត្រីទាំងឡាយដែលកំពុងកាន់មុខតំណែងពិតប្រាកដនៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា មាន ÷

ក/-ឋានន្តរស័ក្តិនាយលេខាធិការ :

- ប្រធានផ្នែក នៅទីស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា
- អនុប្រធានការិយាល័យនៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា

ខ/-ឋានន្តរស័ក្តិលេខាធិការដើមខ្សែ :

- អនុប្រធានផ្នែក នៅទីស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ៧.-**

ការផ្ទេរមន្ត្រីបញ្ចូលទៅក្នុងថ្នាក់នៃឋានន្តរស័ក្តិនីមួយៗរបស់ក្របខ័ណ្ឌលេខាធិការ ត្រូវគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ ។

**ប្រការ៨.-**

មន្ត្រីជាន់ខ្ពស់ដែលមានចែងក្នុងប្រការ២ បើបៀវត្សបច្ចុប្បន្នស្ថិតក្នុងកាំទី២ ត្រូវបន្ថែមអោយ ១ ថ្នាក់ និងក្នុងកាំទី៣ ត្រូវបន្ថែមអោយ ២ ថ្នាក់ ។

មន្ត្រីក្រមការដែលមានចែងក្នុងប្រការ៤ និងមន្ត្រីលេខាធិការដែលមានចែងក្នុងប្រការ៦ បើបៀវត្សបច្ចុប្បន្នស្ថិតនៅក្នុងកាំទី២ ត្រូវចាត់បញ្ចូលទៅក្នុងថ្នាក់លើបន្ទាប់មួយថ្នាក់ ។

ចំពោះមន្ត្រីដែលមានអតីតភាពការងារតិចជាង១៦ឆ្នាំ កំពុងកាន់មុខតំណែង ហើយដែលត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី១ ត្រូវដាក់អោយស្ថិតនៅក្នុងថ្នាក់លេខ៦ ទោះបីមន្ត្រីនោះមានបៀវត្សស្ថិតក្នុងកាំទី២ក៏ដោយ ។

ចំពោះមន្ត្រីដែលមានអតីតភាពការងារតិចជាង៨ឆ្នាំ កំពុងកាន់មុខតំណែង ហើយដែលត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី២ ត្រូវដាក់អោយស្ថិតនៅក្នុងថ្នាក់លេខ១០ ទោះបីមន្ត្រីនោះមានបៀវត្សស្ថិតក្នុងកាំទី២ក៏ដោយ ។

## ជំពូកទី៣
## គោលការណ៍សមាហរណកម្មតាមប្រភេទកាំបៀវត្ស

**ប្រការ៩.-**

មន្ត្រីបុគ្គលិកក្នុងក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជា ក្រៅពីមន្ត្រីបុគ្គលិកដែលត្រូវធ្វើសមាហរណកម្មទៅតាមគោលការណ៍មុខតំណែងខាងលើ ត្រូវធ្វើសមាហរណកម្មតាមប្រភេទកាំបៀវត្ស ត្រូវបញ្ចូលក្នុងក្របខ័ណ្ឌថ្មី ដូចខាងក្រោម :

- ខI ចំពោះអ្នកមានសញ្ញាប័ត្រអនុបណ្ឌិតឡើងទៅ ត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌ "ក"
- ខI ចំពោះអ្នកមានសញ្ញាប័ត្រកំរិតបរិញ្ញាប័ត្រ ត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌ "ខ"
- ខII ត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌ "គ"
- ខIII ខIV និង គI គII គIII គIV ត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌ "ឃ"

ការរៀបបញ្ចូលទៅក្នុងថ្នាក់នីមួយៗនៃក្របខ័ណ្ឌថ្មី ត្រូវបានកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធទី៤នៃប្រកាសនេះ ។

**ប្រការ១០.-**

មន្ត្រីបុគ្គលិកក្នុងក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជា ដែលមានកាំប្រៀវត្សរ៍បច្ចុប្បន្នស្ថិតក្នុងកាំទី៦នៃប្រភេទ ខI ខII ខIII ខIV និង គI គII គIII គIV ហើយមានរយៈពេលចាប់ពី៣ឆ្នាំឡើងទៅ ត្រូវរៀបបញ្ចូលទៅក្នុងថ្នាក់ថ្មី ដោយគិតរយៈពេល៣ឆ្នាំសំរាប់ ១ ថ្នាក់ ។

**ប្រការ១១.-**

ក្រៅពីក្របខ័ណ្ឌមន្ត្រីដែលលក្ខន្តិកៈដោយឡែកកំណត់ ការឡើងឋានន្តរស័ក្តិផ្អែកតាមមុខតំណែងដែលទំនេរ មន្ត្រីបុគ្គលិកក្នុងក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជា ដែលរៀបបញ្ចូលទៅក្នុងថ្នាក់លេខ១១ឡើងទៅ អាចជ្រើសរើសយកចំនួនអតិបរមាស្មើនឹង៣០ភាគរយ លើចំនួនរួមនៃក្របខ័ណ្ឌ បញ្ចូលទៅក្នុងឋានន្តរស័ក្តិទី២ ដោយដាក់ថ្នាក់លេខ១១នៃឋានន្តរស័ក្តិទី៣ បញ្ចូលទៅក្នុងថ្នាក់លេខ១០នៃឋានន្តរស័ក្តិទី២ ហើយរៀបតាមលំដាប់ថ្នាក់ជាបន្តបន្ទាប់ ។

**ប្រការ១២.-**

មន្ត្រីបុគ្គលិកក្នុងក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជាដូចមានចែងក្នុងប្រការ៩ និងប្រការ១១ ដែលបានបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី២ ហើយស្ថិតនៅក្នុងថ្នាក់លេខ៧ឡើងទៅ អាចជ្រើសរើសយកចំនួនអតិបរមាស្មើនឹង៥ភាគរយ លើចំនួនរួមនៃក្របខ័ណ្ឌនីមួយៗ បញ្ចូលទៅក្នុងឋានន្តរស័ក្តិទី១ ដោយដាក់ថ្នាក់លេខ៧នៃឋានន្តរស័ក្តិទី២ បញ្ចូលទៅក្នុងថ្នាក់លេខ៦នៃឋានន្តរស័ក្តិទី១ ហើយរៀបតាមលំដាប់ថ្នាក់ជាបន្តបន្ទាប់ ។

ក្នុងករណីដែលការជ្រើសរើសយកអតិបរមា៥ភាគរយ បញ្ចូលទៅក្នុងឋានន្តរស័ក្តិទី១នេះ មិនបានតាមចំនួនសមស្រប អាចជ្រើសរើសបន្ថែមយកមន្ត្រីដែលស្ថិតក្នុងឋានន្តរស័ក្តិទី២ ហើយមានអតីតភាពការងារចាប់ពី១៦ឆ្នាំឡើងទៅ ហើយមានកាំប្រៀវត្សរ៍បច្ចុប្បន្នខ្ពស់ជាងគេ ។

**ប្រការ១៣.-**

ការជ្រើសរើសបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី២ និងទី១ ដូចមានចែងក្នុងប្រការ១១ និងប្រការ១២ខាងលើ ត្រូវយកចិត្តទុកដាក់ចំពោះមន្ត្រីដែលមានសញ្ញាប័ត្រខ្ពស់ និងអ្នកដែលមានសមត្ថភាពបទពិសោធន៍ក្នុងការបំពេញការងារមានគុណសម្បត្តិខ្ពស់ ។

## ជំពូកទី៤

## បទប្បញ្ញត្តិដោយឡែក

**ប្រការ១៤.-**

មន្ត្រីបុគ្គលិកដែលកំពុងបំរើការងារក្នុងក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជា ហើយមានកំរិតសញ្ញាប័ត្រខ្ពស់ជាងមុខតំណែងរបស់ខ្លួន នៅពេលធ្វើសមាហរណកម្ម ត្រូវផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីទៅតាមកំរិតសញ្ញាប័ត្រ ។

## ប្រការ១៥.-

ក្រៅពីមន្ត្រីក្នុងក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជា ដែលមានចែងក្នុងប្រការ២ខាងលើ ត្រូវធ្វើសមាហរណកម្ម ទៅក្នុងក្របខ័ណ្ឌថ្មី តាមគោលការណ៍ដូចខាងក្រោម ÷

ក/-ចំពោះមន្ត្រីដឹកនាំដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន កII-១ កII-២ កII-៣ ត្រូវផ្ទេរបញ្ចូលទៅក្នុង ក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ទៅក្នុងថ្នាក់លេខ១នៃឋានន្តរស័ក្តិឧត្តមមន្ត្រី

ខ/-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន កII-៤.១ កII-៤.២ កII-៤.៣ ត្រូវផ្ទេរបញ្ចូលទៅក្នុង ឋានន្តរស័ក្តិឧត្តមមន្ត្រី

-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន កII-៦.១ កII-៦.២ និងកII-៥.១ កII-៥.២ ត្រូវផ្ទេរ បញ្ចូលទៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី

-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន កII-៧.១ និងកII-៧.២ ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរ ស័ក្តិអនុមន្ត្រី

ការដាក់បញ្ចូលទៅក្នុងថ្នាក់នៃឋានន្តរស័ក្តិនីមួយៗខាងលើ ត្រូវគិតតាមចំនួនឆ្នាំបំរើការងារ ដូចមានចែងក្នុង ឧបសម្ព័ន្ធទី១នៃប្រកាសនេះ ។

គ/-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន កII-៨.១ និងកII-៨.២ ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរ ស័ក្តិនាយក្រមការ

-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន កII-៩.១ និងកII-៩.២ ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរ ស័ក្តិក្រមការដើមខ្សែ

ការដាក់បញ្ចូលទៅក្នុងថ្នាក់នៃឋានន្តរស័ក្តិនីមួយៗខាងលើ ត្រូវគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានចែង ក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ ។

ឃ/-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន កII-១០.១ និងកII-១០.២ ត្រូវផ្ទេរបញ្ចូលទៅក្នុង ឋានន្តរស័ក្តិនាយលេខាធិការ

-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន កII-១១.១ និងកII-១១.២ ត្រូវផ្ទេរបញ្ចូលទៅក្នុង ឋានន្តរស័ក្តិលេខាធិការដើមខ្សែ

ការដាក់បញ្ចូលទៅក្នុងថ្នាក់នៃឋានន្តរស័ក្តិនីមួយៗខាងលើ ត្រូវគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានចែង ក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ ។

## ប្រការ១៦.-

ចំពោះមន្ត្រីថ្នាក់មន្ត្រីជាន់ខ្ពស់ជំនាន់ទី១ និងជំនាន់ទី២ នៃសាលាភូមិន្ទរដ្ឋបាល ដែលបានទទួលជោគជ័យក្នុងការ ប្រឡងចេញ ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ១២ ឋានន្តរស័ក្តិអនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ។

ចំពោះមន្ត្រីថ្នាក់មធ្យមជំនាន់ទី១ និងជំនាន់ទី២ នៃសាលាភូមិន្ទរដ្ឋបាល ដែលបានទទួលជោគជ័យក្នុងការប្រឡងចេញ ត្រូវបានទទួលអត្ថប្រយោជន៍ដូចខាងក្រោម ÷

- មន្ត្រីដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិបូក២ នៅពេលប្រឡងចូល ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ១៤ ឋានន្តរស័ក្តិអនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់
- មន្ត្រីដែលមានបរិញ្ញាប័ត្រ ឬ សញ្ញាប័ត្រសមមូល នៅពេលប្រលងចូល ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ១៣ ឋានន្តរស័ក្តិអនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

### ប្រការ១៧.~

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

### ប្រការ១៨.~

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាព និងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

### ប្រការ១៩.~

ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០១.

**ទេសាភិបាល**

ជា ចាន់តូ

**កន្លែងទទួល :**

- ដូចប្រការ១៨
  " **ដើម្បីអនុវត្ត** "
- កាលប្បវត្តិ
- ឯកសារ

---

**ចម្លងជូន :**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " **ដើម្បីជូនជ្រាបជាពត៌មាន** "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " **ដើម្បីចុះផ្សាយក្នុងរាជកិច្ច** "

**ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ធ៨.០១ ១៣៥ ប្រក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០១**

# គោលការណ៍

## សមាហរណកម្មមន្ត្រីធនាគារជាតិនៃកម្ពុជាបច្ចុប្បន្ន
## ចូលក្នុងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់

**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី មាន** -

- អគ្គលេខាធិការ អគ្គនាយក អគ្គបេឡា អគ្គពិនិត្យ
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា
- មន្ត្រីដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន កII-៤.១ កII-៤.២ កII-៤.៣ ។

| ឋានន្តរស័ក្តិឧត្តមមន្ត្រី | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | ២៥ឆ្នាំឡើង |
| ថ្នាក់លេខ ៤ | ២២ - ២៥ឆ្នាំ |
| ថ្នាក់លេខ ៥ | ១៩ - ២២ឆ្នាំ |
| ថ្នាក់លេខ ៦ | ១៦ - ១៩ឆ្នាំ |

កំណត់សំគាល់ :

- ក្នុងថ្នាក់នីមួយៗ បើបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី២ ត្រូវបន្ថែមអោយ ១ ថ្នាក់ និងក្នុងកាំទី៣ ត្រូវបន្ថែមអោយ ២ ថ្នាក់
- មន្ត្រីដែលមានអតីតភាពការងារតិចជាង១៦ឆ្នាំ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ៦ ទោះបីបៀវត្សស្ថិតនៅក្នុងកាំទី២ក៏ដោយ ។

**មុខតំណែងដែលត្រូវផ្ទេរបៀវត្សទៅក្នុងឋានន្តរស័ក្តិចរៈមន្ត្រី មាន ÷**

- អគ្គលេខាធិការរង អគ្គនាយករង អគ្គបេឡារង អគ្គពិនិត្យរង
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា
- មន្ត្រីដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន កII-៦.១ កII-៦.២ និង កII-៥.១ កII-៥.២ ។

| ឋានន្តរស័ក្តិចរៈមន្ត្រី | អតីតភាពបំរើការងាររដ្ឋ | |
|---|---|---|
| | ប្រភេទកាំបៀវត្សបច្ចុប្បន្ន កII-៦ | ប្រភេទកាំបៀវត្សបច្ចុប្បន្ន កII-៥ |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | ២៣ឆ្នាំឡើង |
| ថ្នាក់លេខ ៥ | ២៣ឆ្នាំឡើង | ២០ - ២៣ឆ្នាំ |
| ថ្នាក់លេខ ៦ | ២០ - ២៣ឆ្នាំ | ១៧ - ២០ឆ្នាំ |
| ថ្នាក់លេខ ៧ | ១៧ - ២០ឆ្នាំ | ១៤ - ១៧ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៤ - ១៧ឆ្នាំ | ១១ - ១៤ឆ្នាំ |
| ថ្នាក់លេខ ៩ | ១១ - ១៤ឆ្នាំ | ៨ - ១១ឆ្នាំ |
| ថ្នាក់លេខ ១០ | ៨ - ១១ឆ្នាំ | |

កំណត់សំគាល់ :

- ក្នុងថ្នាក់នីមួយៗ បើបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី២ ត្រូវបន្ថែមអោយ ១ ថ្នាក់
- មន្ត្រីដែលមានអតីតភាពការងារតិចជាង៨ឆ្នាំ ក្នុងឋានន្តរស័ក្តិចរៈមន្ត្រី ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ១០ ទោះបីបៀវត្សស្ថិតក្នុងកាំទី២ក៏ដោយ
- មន្ត្រីដែលមានប្រភេទកាំបៀវត្ស កII-៥.១ ត្រូវរៀបបញ្ចូល ដោយគិតពីថ្នាក់លេខ៩ នៃឋានន្តរស័ក្តិចរៈមន្ត្រី ជាចំណុចចាប់ផ្តើម ។

**មុខតំណែងដែលត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី មាន ÷**

- អនុប្រធាននាយកដ្ឋាន
- នាយកសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា
- មន្ត្រីដែលមានប្រភេទកាំបៀវត្សរ៍បច្ចុប្បន្ន កII-៧.១ កII-៧.២ ។

| ឋានន្តរស័ក្តិអនុមន្ត្រី | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | |
| ថ្នាក់លេខ ៤ | |
| ថ្នាក់លេខ ៥ | |
| ថ្នាក់លេខ ៦ | ២៤ឆ្នាំឡើង |
| ថ្នាក់លេខ ៧ | ២១ - ២៤ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៨ - ២១ឆ្នាំ |
| ថ្នាក់លេខ ៩ | ១៥ - ១៨ឆ្នាំ |
| ថ្នាក់លេខ ១០ | ១២ - ១៥ឆ្នាំ |
| ថ្នាក់លេខ ១១ | ៩ - ១២ឆ្នាំ |
| ថ្នាក់លេខ ១២ | ៦ - ៩ឆ្នាំ |
| ថ្នាក់លេខ ១៣ | ៣ - ៦ឆ្នាំ |
| ថ្នាក់លេខ ១៤ | ក្រោម ៣ឆ្នាំ |

<u>កំណត់សំគាល់</u> :

- ក្នុងថ្នាក់នីមួយៗ បើបៀវត្សរ៍មន្ត្រីនោះស្ថិតក្នុងកាំទី២ ត្រូវបន្ថែមអោយ ១ ថ្នាក់ ។

**ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ ៩៨.០១ ១៣៥ប.ក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០១**

# គោលការណ៍
## សមាហរណកម្មមន្ត្រីធនាគារជាតិនៃកម្ពុជាបច្ចុប្បន្ន ចូលក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ

**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការ មាន ÷**

- ប្រធានការិយាល័យ នៅទីស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា
- នាយករងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា
- មន្ត្រីដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន កII-៨.១ កII-៨.២ ។

| ឋានន្តរស័ក្តិនាយក្រមការ | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | ២៥ឆ្នាំឡើង |
| ថ្នាក់លេខ ៤ | ២២ - ២៥ឆ្នាំ |
| ថ្នាក់លេខ ៥ | ១៩ - ២២ឆ្នាំ |
| ថ្នាក់លេខ ៦ | ១៦ - ១៩ឆ្នាំ |

**កំណត់សំគាល់ :**

- ក្នុងថ្នាក់នីមួយៗ បើបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី២ ត្រូវបន្ថែមអោយ ១ ថ្នាក់
- មន្ត្រីដែលមានអតីតភាពការងារតិចជាង១៦ឆ្នាំ ក្នុងឋានន្តរស័ក្តិនាយក្រមការ ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ៦ ទោះបីបៀវត្សស្ថិតនៅក្នុងកាំទី២ក៏ដោយ ។

**មុខតំណែងដែលត្រូវចង្អុលបញ្ជាក់ទៅក្នុងឋានន្តរស័ក្តិក្រុមការដើមខ្សែ មាន ÷**

- អនុប្រធានការិយាល័យ នៅទីស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា
- ប្រធានការិយាល័យ នៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា
- មន្ត្រីដែលមានប្រភេទកាំបៀវត្សរ៍បច្ចុប្បន្ន កII-៩.១ កII-៩.២ ។

| ឋានន្តរស័ក្តិក្រុមការដើមខ្សែ | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | |
| ថ្នាក់លេខ ៤ | |
| ថ្នាក់លេខ ៥ | ២៣ឆ្នាំឡើងទៅ |
| ថ្នាក់លេខ ៦ | ២០ - ២៣ឆ្នាំ |
| ថ្នាក់លេខ ៧ | ១៧ - ២០ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៤ - ១៧ឆ្នាំ |
| ថ្នាក់លេខ ៩ | ១១ - ១៤ឆ្នាំ |
| ថ្នាក់លេខ ១០ | ៨ - ១១ឆ្នាំ |

កំណត់សំគាល់ :

- ក្នុងថ្នាក់នីមួយៗ បើបៀវត្សរ៍មន្ត្រីនោះស្ថិតក្នុងកាំទី២ ត្រូវបន្ថែមអោយ ១ ថ្នាក់
- មន្ត្រីដែលមានអតីតភាពការងារតិចជាង៨ឆ្នាំ ក្នុងឋានន្តរស័ក្តិក្រុមការដើមខ្សែ ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ១០ ទោះបីបៀវត្សរ៍ស្ថិតក្នុងកាំទី២ក៏ដោយ ។

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ ធ៨.០១ ១៣៥ ប្រក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០១

# គោលការណ៍

## សមាហរណកម្មមន្ត្រីធនាគារជាតិនៃកម្ពុជាបច្ចុប្បន្ន ចូលក្នុងក្របខ័ណ្ឌលេខាធិការ

**<u>មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយលេខាធិការ មាន</u>** ÷

- ប្រធានផ្នែក នៅទីស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា
- អនុប្រធានការិយាល័យ នៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា
- មន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន កII-១០.១ កII-១០.២ ។

| ឋានន្តរស័ក្តិនាយលេខាធិការ | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | ២៥ឆ្នាំឡើង |
| ថ្នាក់លេខ ៤ | ២២ - ២៥ឆ្នាំ |
| ថ្នាក់លេខ ៥ | ១៩ - ២២ឆ្នាំ |
| ថ្នាក់លេខ ៦ | ១៦ - ១៩ឆ្នាំ |

<u>កំណត់សំគាល់</u> :

- ក្នុងថ្នាក់នីមួយៗ បើប្រៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី២ ត្រូវបន្ថែមអោយ ១ ថ្នាក់
- មន្ត្រីដែលមានអតីតភាពការងារតិចជាង១៦ឆ្នាំ ក្នុងឋានន្តរស័ក្តិនាយលេខាធិការ ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ៦ ទោះបីប្រៀវត្សស្ថិតក្នុងកាំទី២ក៏ដោយ ។

**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិលេខាធិការដើមខ្សែ មាន ៖**

- អនុប្រធានផ្នែក នៅទីស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា
- ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា
- មន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន កII-១១.១ កII-១១.២ ។

| ឋានន្តរស័ក្តិនាយលេខាធិការដើមខ្សែ | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | |
| ថ្នាក់លេខ ៤ | |
| ថ្នាក់លេខ ៥ | ២៣ឆ្នាំឡើងទៅ |
| ថ្នាក់លេខ ៦ | ២០ - ២៣ឆ្នាំ |
| ថ្នាក់លេខ ៧ | ១៧ - ២០ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៤ - ១៧ឆ្នាំ |
| ថ្នាក់លេខ ៩ | ១១ - ១៤ឆ្នាំ |
| ថ្នាក់លេខ ១០ | ៨ - ១១ឆ្នាំ |

កំណត់សំគាល់ ៖

- ក្នុងថ្នាក់នីមួយៗ បើប្រៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី២ ត្រូវបន្ថែមអោយ ១ ថ្នាក់
- មន្ត្រីដែលមានអតីតភាពការងារតិចជាង៨ឆ្នាំ ក្នុងឋានន្តរស័ក្តិលេខាធិការដើមខ្សែ ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ១០ ទោះបីប្រៀវត្សស្ថិតក្នុងកាំទី២ក៏ដោយ ។

## ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ ធ៨.០១ ១៣៤ ប្រក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០១

## គោលការណ៍សមាហរណកម្មបុគ្គលិកធនាគារជាតិនៃកម្ពុជាបច្ចុប្បន្នចូលក្នុងក្របខ័ណ្ឌប្រភេទ ក

| ឋានន្តរស័ក្តិ<br>និងថ្នាក់ | បៀវត្សបច្ចុប្បន្ន ប្រភេទ ខI<br>ដែលមានសញ្ញាប័ត្រអនុបណ្ឌិតឡើងទៅ | ផ្សេងៗ |
|---|---|---|
| **ឋានន្តរស័ក្តិទី ១** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| **ឋានន្តរស័ក្តិទី ២** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | | |
| ថ្នាក់លេខ ១០ | | |
| **ឋានន្តរស័ក្តិទី ៣** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | | |
| ថ្នាក់លេខ ១០ | ខ I.៦ | |
| ថ្នាក់លេខ ១១ | ខ I.៥ | |
| ថ្នាក់លេខ ១២ | ខ I.៤ | |
| ថ្នាក់លេខ ១៣ | ខ I.៣ | |
| ថ្នាក់លេខ ១៤ | ខ I.២ | |

## គោលការណ៍សមមាត្រណរកម្មបុគ្គលិកធនាគារជាតិនៃកម្ពុជាបម្រុងចូលក្នុងក្របខ័ណ្ឌប្រភេទ ខ

| ឋានន្តរស័ក្តិ និងថ្នាក់ | ប្រៀបធៀបបម្រុង ប្រភេទ ខI ដែលមានសញ្ញាបត្រត្រឹមតែបរិញ្ញាបត្រ | ផ្សេងៗ |
|---|---|---|
| ឋានន្តរស័ក្តិទី ១ | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ឋានន្តរស័ក្តិទី ២ | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | | |
| ថ្នាក់លេខ ១០ | | |
| ឋានន្តរស័ក្តិទី ៣ | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | ខ I.៦ | |
| ថ្នាក់លេខ ១០ | ខ I.៥ | |
| ថ្នាក់លេខ ១១ | ខ I.៤ | |
| ថ្នាក់លេខ ១២ | ខ I.៣ | |
| ថ្នាក់លេខ ១៣ | ខ I.២ | |
| ថ្នាក់លេខ ១៤ | ខ I.១ | |

## គោលការណ៍សមាហរណកម្មបុគ្គលិកធនាគារជាតិនៃកម្ពុជាមកចុះបញ្ជីចូលក្នុងក្របខ័ណ្ឌប្រភេទ គ

| ឋានន្តរស័ក្តិ និងថ្នាក់ | មុខក្របខ័ណ្ឌ ប្រភេទ ខII | ផ្សេងៗ |
|---|---|---|
| **ឋានន្តរស័ក្តិទី ១** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| **ឋានន្តរស័ក្តិទី ២** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | | |
| ថ្នាក់លេខ ១០ | | |
| **ឋានន្តរស័ក្តិទី ៣** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | ខ II.៦ | |
| ថ្នាក់លេខ ១០ | ខ II.៥ | |
| ថ្នាក់លេខ ១១ | ខ II.៤ | |
| ថ្នាក់លេខ ១២ | ខ II.៣ | |
| ថ្នាក់លេខ ១៣ | ខ II.២ | |
| ថ្នាក់លេខ ១៤ | ខ II.១ | |

## គោលការណ៍សមាហរណកម្មបុគ្គលិកធនាគារជាតិនៃកម្ពុជាពីបច្ចុប្បន្នចូលក្នុងក្របខ័ណ្ឌប្រភេទ ឃ

| ឋានន្តរស័ក្តិនិងថ្នាក់ | បៀវត្សរ៍បច្ចុប្បន្ន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ប្រភេទគ I | ប្រភេទគ IV | ប្រភេទខ IV | ប្រភេទគ III | ប្រភេទខ III | ប្រភេទគ II | |
| **ឋានន្តរស័ក្តិទី ១** | | | | | | | |
| ថ្នាក់លេខ ១ | | | | | | | |
| ថ្នាក់លេខ ២ | | | | | | | |
| ថ្នាក់លេខ ៣ | | | | | | | |
| ថ្នាក់លេខ ៤ | | | | | | | |
| ថ្នាក់លេខ ៥ | | | | | | | |
| ថ្នាក់លេខ ៦ | | | | | | | |
| **ឋានន្តរស័ក្តិទី ២** | | | | | | | |
| ថ្នាក់លេខ ១ | | | | | | | |
| ថ្នាក់លេខ ២ | | | | | | | |
| ថ្នាក់លេខ ៣ | | | | | | | |
| ថ្នាក់លេខ ៤ | | | | | | | |
| ថ្នាក់លេខ ៥ | គ I.៦ | | | | | | |
| ថ្នាក់លេខ ៦ | គ I.៥ | | | | | | |
| ថ្នាក់លេខ ៧ | គ I.៤ | | | | | | |
| ថ្នាក់លេខ ៨ | គ I.៣ | | | | | | |
| ថ្នាក់លេខ ៩ | គ I.២ | | | | | | |
| ថ្នាក់លេខ ១០ | គ I.១ | | | | | | |
| **ឋានន្តរស័ក្តិទី ៣** | | | | | | | |
| ថ្នាក់លេខ ១ | | | | | | | |
| ថ្នាក់លេខ ២ | | | | | | | |
| ថ្នាក់លេខ ៣ | | | | | | | |
| ថ្នាក់លេខ ៤ | | | | | | គ II.៦ | |
| ថ្នាក់លេខ ៥ | | | | | ខ III.៦ | គ II.៥ | |
| ថ្នាក់លេខ ៦ | | | | គ III.៦ | ខ III.៥ | គ II.៤ | |
| ថ្នាក់លេខ ៧ | | | ខ IV.៦ | គ III.៥ | ខ III.៤ | គ II.៣ | |
| ថ្នាក់លេខ ៨ | | | ខ IV.៥ | គ III.៤ | ខ III.៣ | គ II.២ | |
| ថ្នាក់លេខ ៩ | | គ IV.៦ | ខ IV.៤ | គ III.៣ | ខ III.២ | គ II.១ | |
| ថ្នាក់លេខ ១០ | | គ IV.៥ | ខ IV.៣ | គ III.២ | ខ III.១ | | |
| ថ្នាក់លេខ ១១ | | គ IV.៤ | ខ IV.២ | គ III.១ | | | |
| ថ្នាក់លេខ ១២ | | គ IV.៣ | ខ IV.១ | | | | |
| ថ្នាក់លេខ ១៣ | | គ IV.២ | | | | | |
| ថ្នាក់លេខ ១៤ | | គ IV.១ | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. [illegible] MoC / M 2001

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០១

# ប្រកាស

## ស្តីពី

## ការដាក់អោយដេញថ្លៃលើកូតាសំលៀកបំពាក់

## ដែលត្រូវបាននាំចេញទៅកាន់សហរដ្ឋអាមេរិកសំរាប់ឆ្នាំ ២០០១

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីអំពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រក្រ/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រក្រ/ ០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីអំពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

- យោងតាមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្ម ទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌ ធ្វើពីកប្បាស, ខ្សែរ, សសៃសិប្បនិម្មិតធ្វើដោយដៃមនុស្ស, សសៃរុក្ខជាតិគ្មានជាតិកប្បាស និង សសៃល្បាយសូត្រ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩
- បានឃើញប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ ៣៦០ពណ៩៩ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌ ដែលជាកម្មវត្ថុនៃការកំណត់បរិមាណ ដោយសហរដ្ឋអាមេរិក
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១:** គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និងដែលបានចុះបញ្ជី នៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម មុនថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០០១ ត្រូវបានអញ្ជើញអោយមកដេញថ្លៃតាមប្រភេទផ្សេងៗនៃកូតា ទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន។

**ប្រការ ២:** រោងចក្រនីមួយៗត្រូវបានអនុញ្ញាតអោយដេញថ្លៃ ដោយគ្មានកំណត់បរិមាណកូតា ដែលដាក់ដេញថ្លៃ តាមប្រភេទនីមួយៗដូចខាងក្រោម៖

| Category | Tender Quantity | Quantity per Batch |
|---|---|---|
| 331/631 | 337,201 doz | មិនកំណត់បរិមាណ |
| 340/640 | 173,924 doz | មិនកំណត់បរិមាណ |
| 345 | 2,955 doz | មិនកំណត់បរិមាណ |
| 347/348/647/648 | 122,444 doz | មិនកំណត់បរិមាណ |
| 352/652 | 57,482 doz | មិនកំណត់បរិមាណ |
| 438 | 34,774 doz | មិនកំណត់បរិមាណ |
| 445/446 | 6,912 doz | មិនកំណត់បរិមាណ |
| 638/639 | 149,298 doz | មិនកំណត់បរិមាណ |
| 645/646 | 25,160 doz | មិនកំណត់បរិមាណ |

**ប្រការ ៣:** ពាក្យដេញថ្លៃនីមួយៗត្រូវភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រ ដែលមានការបញ្ជាក់ពីធនាគារ " Certified Check" ដែលមានតម្លៃ ស្មើនឹង ១០ % នៃតំលៃដេញថ្លៃសរុប ។ មូលប្បទានប័ត្រ នេះត្រូវទូទាត់ជូន គណៈកម្មការគ្រប់គ្រងកូតានាំចេញ (EQMC) ។ ការបង់ប្រាក់កក់ អប្បបរមាមិនគ្រប់ចំនួន ១០ % នៃ តំលៃសរុប នឹងត្រូវចាត់ទុកជា ពាក្យសុំដេញថ្លៃ ដែលមិនគ្រប់លក្ខណៈសម្បត្តិ ចូលរួមដេញថ្លៃ ។

ឧទាហរណ៍ : រោងចក្រ A ដេញថ្លៃ

២០.០០០ ឡូ តំលៃ ៨ ដុល្លា ក្នុងមួយឡូ= ១៦០.០០០ ដុល្លា

សរុប ១៦០.០០០ ដុល្លា

ប្រាក់កក់ ១០ % គឺ ១៦.០០០ ដុល្លា ។

**ប្រការ ៤ :** ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាមប្រភេទកូតានីមួយៗ នឹងត្រូវចាត់ទុកថា ជាការដេញថ្លៃដែលបាន ទទួលជ័យជំនះ ។ បរិមាណកូតានឹងត្រូវបានបែងចែក ជូនអ្នកដេញថ្លៃម្នាក់ៗ ដែលបានទទួលជោគជ័យ រហូតដល់បរិមាណកូតាសរុប ត្រូវបានបែងចែកអស់ជាស្ថាពរ ។

**ប្រការ ៥ :** កូតាដែលមិនទាន់បែងចែក នឹងបន្តទុកសំរាប់ការដេញថ្លៃលើកក្រោយទៀត ។

**ប្រការ ៦ :** តំលៃនៃការចូលរួមដេញថ្លៃ នឹងត្រូវទទួលយក ចំពោះរាល់ការបន្ថែមចំនួន ទសភាគ 10 សេន ដុល្លា អាមេរិក លើថ្លៃឯកត្តា ។

| Category | Minimum Bid | Category | Minimum Bid |
|---|---|---|---|
| 331/631 | US$ 0.20 | 352/652 | US$ 0.20 |
| 340/640 | US$ 0.25 | 438 | US$ 0.50 |
| 345 | US$ 1.00 | 445/446 | US$ 0.50 |
| 347/348/647/6482 | US$ 1.00 | 638/639 | US$ 0.25 |
| | | 645/646 | US$ 0.25 |

**ប្រការ ៧ :** ពាក្យសុំដេញថ្លៃត្រូវដាក់ជូន ប្រធានគណៈកម្មការគ្រប់គ្រងកូតានាំចេញ " EQMC " នៃក្រសួង ពាណិជ្ជកម្ម, ដែលមានទីតាំង នៅអាគារលេខ ២០A ជាន់ទី២, មហាវិថីព្រះនរោត្តម ។ ពាក្យសុំដេញថ្លៃ ត្រូវដាក់ក្នុង ស្រោមសំបុត្របិទជិត ភ្ជាប់ជាមួយនូវមូលប្បទានប័ត្រ ដែលមានទឹកប្រាក់ចំនួន ១០% នៃ តំលៃដេញថ្លៃសរុបពីខាងក្រៅស្រោមសំបុត្រនោះ សំរាប់ជាការផ្ទៀងផ្ទាត់ ។

**ប្រការ ៨ :** កាលបរិច្ឆេទនៃការបើកស្រោមសំបុត្រដេញថ្លៃ គឺនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០០១ វេលាម៉ោង ៨:០០ ព្រឹក នៅទីស្តីការក្រសួងពាណិជ្ជកម្ម អាគារលេខ ២០A ជាន់ទី២ មហាវិថីព្រះនរោត្តម. រាជធានីភ្នំពេញ ។

**ប្រការ ៩ :** កាលបរិច្ឆេទឈប់ទទួលពាក្យសុំដេញថ្លៃ ត្រូវកំណត់នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០០១ វេលាម៉ោង ១៧:០០ ល្ងាច ។

**ប្រការ ១០:** លទ្ធផលនៃការដេញថ្លៃនឹងត្រូវប្រកាសជាសាធារណៈ តាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០១ វេលាម៉ោង ៨:០០ ព្រឹក ។

**ប្រការ ១១:** អ្នកចូលរួមដេញថ្លៃដែលបានទទួលជោគជ័យ នឹងអាចទទួលយកកូតារបស់ខ្លួន ទៅប្រើប្រាស់បានចាប់ពីថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០០១ បន្ទាប់ពីបានទូទាត់ តំលៃដេញថ្លៃដែលនៅសេសសល់ រួចហើយ ។

**ប្រការ ១២:** អ្នកចូលរួមដេញថ្លៃដែលបានទទួលជោគជ័យ ហើយខកខានមិនបានទទួលយក បរិមាណកូតារបស់ខ្លួន នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០០១ទេ នឹងត្រូវរឹបអូសយកប្រាក់កក់ ១០% ហើយបរិមាណកូតាដែលមិនបានទទួលយកនោះ ត្រូវបន្តទុកសំរាប់ការដេញថ្លៃលើកក្រោយ ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធក្នុងការមិនអនុញ្ញាតឱ្យក្រុមហ៊ុននោះ ចូលរួមដេញថ្លៃកូតាលើកក្រោយ១ទៀត ។

**ប្រការ ១៣:** អ្នកចូលរួមដេញថ្លៃដែលមិនបានទទួលជោគជ័យ នឹងត្រូវផ្តល់ជូនវិញភ្លាមនូវប្រាក់កក់ ១០% របស់ខ្លួន ។

**ប្រការ ១៤ :** កូតាដែលទទួលបានតាមរយៈការដេញថ្លៃនេះ នឹងត្រូវបានប្រើប្រាស់សំរាប់តែឆ្នាំសារពើពន្ធ២០០១ ប៉ុណ្ណោះ. យោងតាមកិច្ចព្រមព្រៀងវាយនភ័ណ្ឌរវាងសហរដ្ឋអាមេរិក និងកម្ពុជា នាឆ្នាំ១៩៩៩ ។

**ប្រការ ១៥ :** សេចក្តីសំរេចរបស់គណៈកម្មការគ្រប់គ្រងកូតានាំចេញ នៅក្នុងការអនុវត្តការដេញថ្លៃនេះ គឺជាការសំរេចចុងក្រោយ ។

**ប្រការ ១៦ :** នាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី, អគ្គនាយកបច្ចេកទេស, ប្រធាននាយកដ្ឋានកាំកុងត្រូល, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ប្រធាននាយកដ្ឋានរដ្ឋបាល, ផលិតករសំលៀកបំពាក់ និងសមាជិក គណៈកម្មការគ្រប់គ្រងកូតានាំចេញ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** រង

**ចម-ប្រសិទ្ធ**

**ចំលងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- រាជកិច្ច ✓
- ទូរទស្សន៍ជាតិ, វិទ្យុជាតិ និង កាសែតជាតិ "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

**Ministry of Commerce**

No. 267 MoC / M 2001

***From the Minister's Desk***

**Phnom Penh, October 07, 2001**

# PRAKAS

## On the Tender for Quota on Garments to be Exported to the United States in FY 2001

## THE MINISTER OF COMMERCE

- Pursuant to the Constitution of the Kingdom of Cambodia;
- Pursuant to the Royal Decree No 02/NS/94 dated July 20, 1994 on the Organization and Functioning of the Council of Ministers;
- Pursuant to the Royal Decree No NS/RK/1198/72 dated November 30, 1998 on the Appointment of the Royal Government of Cambodia;
- Pursuant to the Royal Decree No NS/RK/0196/16 dated January 24, 1996 on the Creation of the Ministry of Commerce;
- Pursuant to the Sub-Decree No 54 AK dated September 22, 1997 on the Organization and Functioning of the Ministry of Commerce;
- Pursuant to the Agreement Relating to Trade in Cotton, Wool, Man-made fiber, Non-cotton Vegetable Fiber and Silk Blend Textiles and Textile Products between the Royal Government of Cambodia and the Government of the United States of America, dated January 20, 1999;
- Pursuant to the Council of Ministers' meeting of January 29, 1999;
- Pursuant to the Prakas of the Ministry of Commerce No 360 MoC/M 99 dated 01/02/99 on the establishment of the Export Quotas Management Committee for textiles and textile products subject to limitations by the United States of America;
- Seen the needs of the Ministry;

## DECIDES

**Article 1.** Garment factories in operation and duly registered with the Trade Preferences Department of the Ministry of Commerce before October 17, 2001 are invited to tender for Quota Categories in accordance to their production capabilities.

**Article 2.** Each factory is permitted to tender for non-limited quantity of quota put up for tender in each of the following categories :

| *Category* | *Tender Quantity* | *Quantity per Batch* |
|---|---|---|
| 331/631 | 337,201 doz | Not Limited |
| 340/640 | 173,924 doz | Not Limited |
| 345 | 2,955 doz | Not Limited |
| 347/348/647/648 | 122,444 doz | Not Limited |
| 352/652 | 57,482 doz | Not Limited |
| 438 | 34,774 doz | Not Limited |
| 445/446 | 6,912 doz | Not Limited |
| 638/639 | 149,298 doz | Not Limited |
| 645/646 | 25,160 doz | Not Limited |

**Article 3.** Each tender bid must be accompanied by a certified check bearing the value equivalent to 10% of the bid value. Certified checks are to be made payable to the Export Quotas Management Committee. Any shortfall in the minimum deposit of the 10% will disqualify the tender bid.

***Example*** :
**Factory A**

| | | |
|---|---|---|
| 20,000 Doz | at US$ 8 per Doz | = US$ 160,000 |
| | Total | = US$ 160,000 |
| | 10% deposit | = US$ 16,000 |

**Article 4.** The highest bids in each category will be successful. Quota will be distributed to each successful bidder until the total quantity of quota is fully allocated.

**Article 5.** Unallocated quota will be carried over to the next tender.

**Article 6.** Tender bids are now accepted for any addition of USD 10 Cents .

| Category | Minimum Bid | Category | Minimum Bid |
|---|---|---|---|
| 331/631 | US$ 0.20 | 352/652 | US$ 0.20 |
| 340/640 | US$ 0.25 | 438 | US$ 0.50 |
| 345 | US$ 1.00 | 445/446 | US$ 0.50 |
| 347/348/647/6482 | US$ 1.00 | 638/639 | US$ 0.25 |
| | | 645/646 | US$ 0.25 |

**Article 7.** Tenders are to be submitted to the EQMC Chairman, at the Ministry of Commerce, second floor No 20A, Preah Norodom Blvd.

Tender Bids are to be submitted in sealed envelopes with the 10% deposit certified check attached to the outside of the tender envelope for verification.

**Article 8.** The opening date for tenders is October 18, 2001 at 8:00 am at the Ministry of Commerce, Building A, 2nd Floor, 20 Preah Norodom Boulevard, Phnom Penh.

**Article 9.** The Closing date for reception of tender offers is at 5:00 pm, October 17, 2001.

**Article 10.** Results of the tender will be publicly announced by Prakas of the Ministry of Commerce on October 19, 2001 at 8:00 am.

**Article 11.** Successful tender shall be taken up by October 20, 2001 after payment of the balance of tender price.

**Article 12.** Failure by successful bidders to take up the quota by October 30, 2001 will result in the 10% deposit being confiscated and the quota quantity carried over to the next tender event. The Ministry of Commerce reserves its own right to prohibit those companies to participate in the next quota auctions.

**Article 13.** Unsuccessful bidders will have their 10% deposit refunded immediately.

**Article 14.** Quota acquired through this tender will be used only for FY 2001 in accordance to the US-Cambodia Textiles Agreement of 1999.

**Article 15.** The decision of the EQMC in this exercise will be final.

**Article 16.** The Director of Cabinet, the Technical Director General, the Director of CAMCONTROL Department, the Director of Trade Preferences Department, the Director of Administrative Affairs, all garment manufacturers and members of the Export Quotas Management Committee shall implement this Prakas.

The Minister of Commerce

**CHAM PRASIDH**

CC.
Cabinet of H.E. Samdech Prime Minister
Cabinet of H.E. DPM & Co-Minister of Interior
Cabinet of the Council of Ministers
Ministry of Economy and Finance
Ministry of Industry, Mines and Energy
Ministry of Social Action, Labor, Vocational Training and Youth Rehabilitation
"For information"
Royal Gazette ✓
National TV / Radio / Written press "For publication"
MOC Archives

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion king

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry,Mines and Energy

N°៧៥៣ ឧ.រ.ថ.ប្រក

រាជធានី-ភ្នំពេញ,ថ្ងៃទី.០៤.....ខែ.តុលា....ឆ្នាំ២០០១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ. បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ១៧៣២/០១ គ.វ.ក ចុះថ្ងៃទី ០៦.០៦.២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- បានឃើញប្រកាសលេខ ២០០ ប.ស្ត.ប្រ.ក វិបបស្ត ចុះថ្ងៃទី ១៤.០៩.២០០១ របស់ក្រសួងបរិស្ថាន ។
- បានឃើញលិខិតលេខ ៣៣៨៦ ល អ.ស ចុះថ្ងៃទី ០៩.១២.៩៨ របស់សាលាក្រុងភ្នំពេញ ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ឌីអេ ខបភើរេសិន អិលធីឌី ចុះថ្ងៃទី ២៧.០៩.២០០១ ។

## សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ឌីអេ ខបភើរេសិន អិលធីឌី ( D.A CORPORATION, LTD.) តំណាងដោយលោក CHUNG BYUNG MIN សញ្ជាតិ កូរ៉េ អាយុ ៥៤ ឆ្នាំ ភេទប្រុស កាន់លិខិតឆ្លងដែន លេខ NW0632780 ចុះថ្ងៃទី 01.02.01 បង្កើតរោងចក្រ " ចាក់សំលៀកបំពាក់ " ដែលមានឈ្មោះថា " ឌីអេ ខបភើរេសិន " មានទីតាំងស្ថិតនៅដីឡូតិ៍លេខ ៣១១ ផ្លូវលេខ ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ២ : ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានសំរេច ក្នុងរយៈពេល ០៦ខែ ដោយរាប់បញ្ចូលទាំងរយៈពេលសាកល្បងផង ។

ប្រការ៣ : រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ " ចាក់សំលៀកបំពាក់ " ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤ : ក្រុមហ៊ុនត្រូវលើកបង្ហាញ ផ្លាកឈ្មោះរោងចក្រ របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥ : ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការ អនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវស៊ើវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៧: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពី ការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធ នឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសចំពោះ នឹងប្រការណា មួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវអស់សុពលភាព ។

ប្រការ៩ : អគ្គនាយកឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ឌីអេ ឧបភើរេសិន អិលធីឌី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ១០ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច-ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជាពត៌មាន "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion king

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry,Mines and Energy
N°៦៥៤ ឧ.ថ.ក-ប្រក

រាជធានី-ភ្នំពេញ,ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០០១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ. បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ២១៥៣/០១ គ.រ.ក ចុះថ្ងៃទី ១៦.០៧.២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- បានឃើញប្រកាសលេខ ១៩០ប.ស្ត.ប្រ.ក វហបស្ត ចុះថ្ងៃទី ២០.០៨.២០០១ របស់ក្រសួងបរិស្ថាន ។
- បានឃើញលិខិតលេខ ០៩៨ ល.អ ចុះថ្ងៃទី ២២.០៩.៩៧ របស់សាលាខេត្តកណ្តាល ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន យេនយូអ៊ិន ហ្គាមេន ( ខេមបូឌា ) ខូ អិលធីឌី ចុះថ្ងៃទី០៩ ០៨.២០០១។

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន យេនយូអ៊ិន ហ្គាមេន ( ខេមបូឌា ) ខូ អិលធីឌី ( GENUINE GARMENT ( CAMBODIA) Co., LTD. ) តំណាងដោយលោក YEH SHENG MAO សញ្ជាតិចិន ( តៃវ៉ាន់) អាយុ ៦០ឆ្នាំ ភេទប្រុស កាន់លិខិតឆ្លងដែនលេខM20172914 ចុះថ្ងៃទី19.11.99 បង្កើតរោងចក្រ " កាត់ដេរសំលៀកបំពាក់ " ដែលមានឈ្មោះថា "យេនយូអ៊ិន ហ្គាមេន ( ខេមបូឌា) " មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ៤ ភូមិគល់ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ។ល។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ទូរសារ : (៨៥៥) ២៣-៤២៨ ២៦៣
45 Preah Norodom Boulevard,Khan Daun Penh,Phnom Penh (Cambodia) Tel / Fax (855) 23-428 263

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ______

ប្រការ២ : ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានសំរេច ក្នុងរយៈពេល ០៦ខែ ដោយរាប់បញ្ចូលទាំងរយៈពេលសាកល្បងផង ។

ប្រការ៣ : រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ " កាត់ដេរសំលៀកបំពាក់ " ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤ : ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥ : ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៧ : ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ៨ : ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវអស់សុពលភាព ។

ប្រការ៩ : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និង ប្រធានក្រុមហ៊ុន យេនយូអ៊ិន ហ្គាមេន ( ខេមបូឌា ) ខូ អិលធីឌី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ១០ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច-ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តកណ្តាល

" ដើម្បីជូនជ្រាបជាពត៌មាន "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
និង អធិការកិច្ច
Ministry of National Assembly-Senate Relations and Inspection

លេខ : 006/01 ទ.រ.ព.អ សសក

រាជធានីភ្នំពេញ, ថ្ងៃទី 02 ខែ ១០ ឆ្នាំ 2001

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល នៅក្នុងក្របខ័ណ្ឌថ្មី

## រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការ រៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/០៦ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ។

-បានឃើញលិខិតលេខ ៧១៥ មស.ត្រ.រ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

- តាមសំណើរបស់នាយកដ្ឋានរដ្ឋបាល-បុគ្គលិក ។

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការ ធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល នៅក្នុងក្របខ័ណ្ឌថ្មី នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ដែលមានសមាសភាពដូចខាងក្រោម ៖